  

# ផែនការសកម្មភាពសម្រាប់ការតភ្ជាប់សេដ្ឋកិច្ច កម្ពុជា-ឡាវ-វៀតណាម ដល់ឆ្នាំ ២០៣០

# ACTION PLAN FOR CAMBODIA-LAOS-VIET NAM ECONOMIC CONNECTIVITY UP TO 2030

Cambodia-Laos-Viet Nam (CLV)

Action Plan For Economic Connectivity up to 2030

បកប្រែក្រៅផ្លូវការដោយ៖ ក្រសួងពាណិជ្ជកម្ម

# ផែនការសកម្មភាពសម្រាប់ការតភ្ជាប់សេដ្ឋកិច្ច កម្ពុជា-ឡាវ-វៀតណាម ដល់ឆ្នាំ ២០៣០

# មាតិកា


<u>ពិពណ៌នា</u> <u>ទំព័រ</u>

## ផ្នែកទី១
## សាវតា និងបរិបទនៃការតភ្ជាប់សេដ្ឋកិច្ចកម្ពុជា-ឡាវ-វៀតណាម

**I. សាវតា** ........................................ ១

**II. បរិបទនៃការតភ្ជាប់សេដ្ឋកិច្ចកម្ពុជា-ឡាវ-វៀតណាម** ........................................ ២

២.១. កាលានុវត្តភាព ........................................ ២

២.២. បញ្ហាប្រឈមនានា ........................................ ៣

**III. បញ្ហាចម្បងនានាដែលត្រូវដោះស្រាយ** ........................................ ៤

៣.១. ការតភ្ជាប់ស្ថាប័ន ........................................ ៤

៣.២. ការតភ្ជាប់ហេដ្ឋារចនាសម្ព័ន្ធ និងសេដ្ឋកិច្ច ........................................ ៤

៣.៣. ការតភ្ជាប់រវាងប្រជាជន និងប្រជាជន ........................................ ៥

## ផ្នែកទី ២
## ទស្សនៈ គោលបំណង និងមាតិកា នៃការតភ្ជាប់សេដ្ឋកិច្ចប្រទេសទាំងបី

**I. ទស្សនៈ** ........................................ ៦

**II. គោលបំណង** ........................................ ៦

**III. មាតិកានៃការតភ្ជាប់** ........................................ ៧

៣.១. ការតភ្ជាប់ស្ថាប័ន ........................................ ៧

៣.២. ការតភ្ជាប់ហេដ្ឋារចនាសម្ព័ន្ធ ........................................ ៧

៣.៣. ការតភ្ជាប់រវាងប្រជាជន និងប្រជាជន ........................................ ៧

# ផ្នែកទី ៣

# យុទ្ធសាស្ត្រសំខាន់ៗសម្រាប់បង្កើន ការតភ្ជាប់សេដ្ឋកិច្ចកម្ពុជា-ឡាវ-វៀតណាម


**I. ការតភ្ជាប់ស្ថាប័ន** ........ ៨

**II. ការតភ្ជាប់ហេដ្ឋារចនាសម្ព័ន្ធ និងការតភ្ជាប់វិស័យសេដ្ឋកិច្ចសំខាន់ៗ** ........ ៩

២.១. ហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន ........ ៩

២.២. ហេដ្ឋារចនាសម្ព័ន្ធថាមពល ........ ១១

២.៣. ប្រៃសណីយ៍ និងទូរគមនាគមន៍ ........ ១២

២.៤. វិនិយោគ ........ ១២

២.៥. ពាណិជ្ជកម្ម និងបញ្ហាទាក់ទងនឹងពាណិជ្ជកម្ម ........ ១៣

២.៦. ឧស្សាហកម្មសំខាន់ៗ ........ ១៤

២.៧. វិស័យហិរញ្ញវត្ថុ និងធនាគារ ........ ១៧

២.៨. ធនធានធម្មជាតិ បរិស្ថាន និងការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ ........ ១៧

២.៩. វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ........ ១៩

២.១០. ការសម្អាតមីន និងអាវុធយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ (UXO) ........ ១៩

**III. ការតភ្ជាប់ទំនាក់ទំនងរវាងប្រជាជននិងប្រជាជន និងកិច្ចសហប្រតិបត្តិការតាមតំបន់ព្រំដែន** ........ ១៩

៣.១. ការអប់រំ និងបណ្ដុះបណ្ដាល ........ ១៩

៣.២. វិស័យសុខាភិបាល ........ ២០

៣.៣. កិច្ចសហប្រតិបត្តិការក្នុងការប្រើប្រាស់កម្លាំងពលកម្ម ........ ២១

៣.៤. វប្បធម៌ កីឡា និងទេសចរណ៍ ........ ២១
៣.៥. កិច្ចសហប្រតិបត្តិការតាមព្រំដែន និងការតភ្ជាប់រវាងប្រជាជននិងប្រជាជន ........ ២៣

## ផ្នែកទី៤

## ធនធានហិរញ្ញវត្ថុ និងការរៀបចំការអនុវត្តការតភ្ជាប់

**I. ធនធានហិរញ្ញវត្ថុ** ........ ២៥
**II. ការរៀបចំអនុវត្ត** ........ ២៦

# ផ្នែកទី១
# សាវតា និងបរិបទនៃការតភ្ជាប់សេដ្ឋកិច្ចកម្ពុជា-ឡាវ-វៀតណាម

## I. សាវតា

នៅឯកិច្ចប្រជុំកំពូលកម្ពុជា-ឡាវ-វៀតណាម ស្តីពីការអភិវឌ្ឍតំបន់ត្រីកោណ លើកទី៨ (8th CLV-DTA Summit) ដែលបានប្រព្រឹត្តទៅកាលពីថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១៤ នៅទីក្រុងវៀងច័ន្ទ ប្រទេសឡាវ ឯកឧត្តម **Nguyen Tan Dung** នាយករដ្ឋមន្ត្រីវៀតណាម បានស្នើរដ្ឋាភិបាលរបស់ប្រទេសទាំងបី កម្ពុជា ឡាវ និងវៀតណាម គួរយកចិត្តទុកដាក់ចាត់វិធានការអនុវត្តឲ្យមានប្រសិទ្ធភាព ដែលអាចអនុវត្តបាន និងមានភាពបត់បែន ដើម្បីពង្រឹង និងពង្រីកនូវកិច្ចសហប្រតិបត្តិការត្រីភាគី។ ប្រមុខដឹកនាំប្រទេសទាំងបី បានពិភាក្សា និងឯកភាពក្នុងការបង្កើន និងពង្រីកក្របខណ្ឌសហប្រតិបត្តិការអភិវឌ្ឍតំបន់ត្រីកោណកម្ពុជា-ឡាវ-វៀតណាម និងចាត់តាំងគណៈកម្មាធិការសម្របសម្រួលចម្រុះដើម្បីសម្របសម្រួលជាមួយស្ថាប័នពាក់ព័ន្ធ ក្នុងការអភិវឌ្ឍគម្រោងតភ្ជាប់សេដ្ឋកិច្ចនៃប្រទេសទាំងបីដែលសេចក្តីព្រាងផែនការសម្រាប់ការតភ្ជាប់សេដ្ឋកិច្ចនៃប្រទេសទាំងបី ត្រូវបានដាក់ជូនប្រមុខដឹកនាំប្រទេសទាំងបីសម្រាប់ពិចារណា និងអនុម័ត នៅឯកិច្ចប្រជុំកំពូលកម្ពុជា-ឡាវ-វៀតណាម ស្តីពីការអភិវឌ្ឍតំបន់ត្រីកោណ លើកទី១០ (10th CLV-DTA Summit) ដែលបានប្រព្រឹត្តទៅកាលពីខែមីនា ឆ្នាំ២០១៨ នៅប្រទេសវៀតណាម។

ការតភ្ជាប់សេដ្ឋកិច្ចបានក្លាយជានិន្នាការដ៏សំខាន់មួយនៅក្នុងសកលលោក និងជាពិសេសក្នុងចំណោមប្រជាជាតិនានា នៅក្នុងតំបន់អាស៊ី។ នៅតំបន់អាស៊ីអាគ្នេយ៍ សហគមន៍សេដ្ឋកិច្ចអាស៊ាន (ASEAN Economic Community) ដែលបានចូលជាធរមាននៅចុងឆ្នាំ២០១៥ ហើយបណ្តាប្រទេសក្នុងតំបន់ បាននឹងកំពុងអនុវត្តយ៉ាងសកម្មនូវផែនការមេស្តីពីការតភ្ជាប់អាស៊ាន ២០២៥ (Master Plan on ASEAN Connectivity 2025-MPAC 2025)។ ប្រទេសមហាអំណាចមួយចំនួននៅក្នុងតំបន់ រួមមាន ប្រទេសចិន ជប៉ុន អាមេរិក និងប្រទេសផ្សេងទៀត បានស្នើនូវគំនិតផ្តួចផ្តើមសម្រាប់កិច្ចសហប្រតិបត្តិការជាបន្តបន្ទាប់ សំដៅជានាលើកកម្ពស់វិស័យពាណិជ្ជកម្មក្នុងតំបន់ និងខ្សែសង្វាក់តម្លៃ រួមមានការតភ្ជាប់សេដ្ឋកិច្ចជាមួយបណ្តាប្រទេសអាស៊ាន។ ទន្ទឹមនឹងនេះ ប្រទេសកម្ពុជា ឡាវ និងវៀតណាម បាននឹងកំពុងប្រឹងប្រែងអភិវឌ្ឍ និងធ្វើសមាហរណកម្មទៅក្នុងសេដ្ឋកិច្ចតំបន់ និងសកលក្នុងទ្រង់ទ្រាយធំ។ បន្ថែមពីលើការចូលរួមយ៉ាងសកម្មក្នុងកម្មវិធីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច និងគំនិតផ្តួចផ្តើមនានាក្នុងក្របខណ្ឌអាស៊ាន ប្រទេសទាំងបីក៏បានចូលរួមអនុវត្តគំនិតផ្តួចផ្តើមជាបន្តបន្ទាប់ ស្តីពីកិច្ចសហប្រតិបត្តិការអនុតំបន់ មានជាអាទិ៍ កិច្ចសហប្រតិបត្តិការអភិវឌ្ឍតំបន់ត្រីកោណ កម្ពុជា-ឡាវ-វៀតណាម (CLV-DTA) កិច្ចសហប្រតិបត្តិការ កម្ពុជា-ឡាវ-មីយ៉ាន់ម៉ា-វៀតណាម (CLMV) និងកម្មវិធីមហាអនុតំបន់មេគង្គ (Greater Mekong Sub-Region - GMS) ដែលកិច្ចសហប្រតិបត្តិការទាំងនេះ បានផ្តល់នូវបទពិសោធន៍ និងសមិទ្ធិផលគួរជាទីកត់សម្គាល់។ ទោះយ៉ាងនេះក្តី លទ្ធផលនៃកិច្ចសហប្រតិបត្តិការ និងការតភ្ជាប់សេដ្ឋកិច្ចរវាងប្រទេសទាំងបី មិនទាន់ឆ្លើយតបទៅនឹងសក្តានុពលកម្រិតខ្ពស់របស់ កម្ពុជា-ឡាវ-វៀតណាមនៅឡើយ។ កង្វះខាត

នៃកិច្ចសហប្រតិបត្តិការស្ថាប័ន ហេដ្ឋារចនាសម្ព័ន្ធ និងធនធានមនុស្ស នៅតែជាបញ្ហាប្រឈម ដែលធ្វើឲ្យកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច និងការតភ្ជាប់ប្រទេសទាំងបី នាពេលកន្លងមក មិនទាន់មានប្រសិទ្ធភាពនៅឡើយ។

ក្រោមបរិបទខាងលើ ការរៀបចំ និងការអនុវត្តផែនការសកម្មភាពសម្រាប់ការតភ្ជាប់សេដ្ឋកិច្ច កម្ពុជា-ឡាវ-វៀតណាម គឺជាភារកិច្ចចាំបាច់ និងមានសារៈសំខាន់ សម្រាប់កិច្ចសម្របសម្រួលសេដ្ឋកិច្ចប្រទេសទាំងបី ក៏ដូចជាបង្កើននូវការប្រកួតប្រជែង និងសមត្ថភាពក្នុងការទាក់ទាញវិនិយោគបរទេស ព្រមទាំងកាត់បន្ថយគម្លាតនៃការអភិវឌ្ឍរបស់ប្រទេសទាំងបី ជាមួយបណ្តាប្រទេសសមាជិកអាស៊ានផ្សេងទៀត ព្រមទាំងពន្លឿនការតភ្ជាប់សេដ្ឋកិច្ចនៅក្នុងសហគមន៍សេដ្ឋកិច្ចអាស៊ាន និងធ្វើសមាហរណកម្មទៅក្នុងសេដ្ឋកិច្ចតំបន់ និងសកលលោក ប្រកបដោយស័ក្តិសិទ្ធភាពខ្ពស់ជាងមុន។

## II. បរិបទនៃការតភ្ជាប់សេដ្ឋកិច្ចកម្ពុជា-ឡាវ-វៀតណាម

### ២.១. កាលានុវត្តភាព

១. ប្រមុខដឹកនាំកម្ពុជា-ឡាវ-វៀតណាម មានការសម្រេចចិត្តខ្ពស់ផ្នែកនយោបាយក្នុងការតភ្ជាប់សេដ្ឋកិច្ចប្រទេសទាំងបី ដើម្បីលើកកម្ពស់កម្រិតកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងបី។

២. ការតភ្ជាប់សេដ្ឋកិច្ចបានដើរតួនាទីយ៉ាងសំខាន់ ក្នុងការសម្របសម្រួលសមាហរណកម្មសេដ្ឋកិច្ចនៅក្នុងតំបន់។ សហគមន៍សេដ្ឋកិច្ចអាស៊ាន គឺជាសសរស្តម្ភមួយក្នុងចំណោមសសរស្តម្ភសំខាន់ៗទាំងបីរបស់សហគមន៍អាស៊ានចាប់តាំងពីចុងឆ្នាំ២០១៥។ ក្នុងកំឡុងឆ្នាំ២០១១-២០១៥ ប្រទេសក្នុងតំបន់បានអនុវត្តផែនការមេ ស្តីពីការតភ្ជាប់អាស៊ាន២០២៥ (MPAC 2025) ហើយផែនការនេះនឹងត្រូវអនុវត្តបន្តទៀត រហូតដល់ឆ្នាំ២០២៥ ។

៣. កម្ពុជា ឡាវ និងវៀតណាម ទទួលបានផលប្រយោជន៍ពីទីតាំងភូមិសាស្ត្រ ធនធានធម្មជាតិ និងធនធានមនុស្ស ព្រមទាំងវប្បធម៌សម្បូរបែបរបស់ខ្លួន និងមានព្រំប្រទល់វែងជាប់គ្នា ច្រកព្រំដែន និងតំបន់សេដ្ឋកិច្ចនានាប្រកបដោយហេដ្ឋារចនាសម្ព័ន្ធល្អ។ ប្រទេសទាំងបីមានទីតាំង ជាប់ច្រករបៀងសេដ្ឋកិច្ចតំបន់សំខាន់ៗ ដូចជា ច្រករបៀងសេដ្ឋកិច្ចចិន-ឧបទ្វីបឥណ្ឌូចិន ស្ថិតលើអ័ក្សជើង-ត្បូង ច្រករបៀងសេដ្ឋកិច្ចភាគខាងកើត-លិច និងច្រករបៀងសេដ្ឋកិច្ចភាគខាងត្បូង ។ល។ ទីតាំងយុទ្ធសាស្ត្រនេះ ជានានូវអត្ថប្រយោជន៍ក្នុងការជំរុញការតភ្ជាប់ពាណិជ្ជកម្ម និងទេសចរណ៍ ក៏ដូចជាបង្កើនការទាក់ទាញវិនិយោគិនផ្ទាល់ពីបរទេស។

៤. ប្រទេសទាំងបីមានទំនាក់ទំនងមិត្តភាពជាអ្នកជិតខាងល្អជាយូរអង្វែង ដោយទទួលបានសមិទ្ធិផលគួរឲ្យកត់សម្គាល់នៅក្នុងកិច្ចសហប្រតិបត្តិការ និងការតភ្ជាប់ផ្នែកសេដ្ឋកិច្ច។ ប្រទេសទាំងបីមានស្ថិរភាពនយោបាយ និងសេដ្ឋកិច្ចប្រកបដោយថាមវន្តជាមួយអត្រាកំណើនខ្ពស់។ ទាំងនេះមិនត្រឹមតែជាលក្ខខណ្ឌចាំបាច់ក្នុងការធានាសម្រេចឲ្យបាននូវការតភ្ជាប់សេដ្ឋកិច្ចរវាងប្រទេសកម្ពុជា-ឡាវ-វៀតណាមនោះទេ ប៉ុន្តែក៏ជាមូលដ្ឋានគ្រឹះសម្រាប់ប្រទេសទាំងបីតភ្ជាប់គ្នា ដើម្បីលើកកម្ពស់សមត្ថភាពប្រកួតប្រជែងរបស់ខ្លួន ទល់នឹងសេដ្ឋកិច្ចប្រទេសដទៃទៀតនៅក្នុងតំបន់ និងភាពទាក់ទាញវិនិយោគិនពីបរទេស។

៥. កម្ពុជា-ឡាវ-វៀតណាម បាននឹងកំពុងទទួលបានអត្ថប្រយោជន៍រួមពីកិច្ចសហប្រតិបត្តិការ និងការតភ្ជាប់ផ្នែកសេដ្ឋកិច្ចដោយមានសក្តានុពលក្នុងការបំពេញបន្ថែមឲ្យគ្នាទៅវិញទៅមក។ ឧទាហរណ៍ ឡាវមានសក្តានុពលខ្លាំង ក្នុងការ

ផលិត និងផ្គត់ផ្គង់ថាមពលវារីអគ្គិសនី ខណៈដែលកម្ពុជាមានតម្រូវការនាំចូលថាមពលអគ្គិសនី។ ឡាវគឺជាប្រទេសគ្មានដែនសមុទ្រ ខណៈដែលកម្ពុជា និងវៀតណាមមានឆ្នេរសមុទ្រ ប្រកបដោយសក្តានុពលក្នុងការអភិវឌ្ឍ មានជាអាទិ៍ កំពង់ផែសមុទ្រ ការដឹកជញ្ជូនតាមផ្លូវសមុទ្រ គ្រឿងសមុទ្រ និងទេសចរណ៍ដែនសមុទ្រ ជាដើម។

៦. ប្រទេសទាំងបីបានឈានចូលការធ្វើសមាហរណកម្មសេដ្ឋកិច្ចក្នុងតំបន់ និងសកល ជាពិសេសការចូលរួមក្នុងកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី (Free Trade Agreements - FTAs) នាយុគសម័យថ្មី។ ប្រទេសទាំងបីមានបទពិសោធន៍យូរអង្វែងស្តីពីកិច្ចសហប្រតិបត្តិការត្រីភាគី ក្រោមក្របខណ្ឌគំនិតផ្តួចផ្តើមអភិវឌ្ឍន៍តំបន់ត្រីកោណកម្ពុជា-ឡាវ-វៀតណាម ដោយទទួលបានសមិទ្ធិផលជាច្រើនគួរឲ្យកត់សម្គាល់។ សមិទ្ធិផលទាំងនេះមានសារៈសំខាន់បំផុត ក្នុងការជំរុញការតភ្ជាប់សេដ្ឋកិច្ចត្រីភាគី នាពេលខាងមុខ។

៧.យុទ្ធសាស្ត្រ និងផែនការអភិវឌ្ឍន៍របស់ប្រទេសទាំងបីផ្តល់អាទិភាពចម្បងលើការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធធនធានមនុស្ស និងកំណែទម្រង់ស្ថាប័ន។

## ២.២. បញ្ហាប្រឈមនានា

១. ធនធានហិរញ្ញវត្ថុរបស់ប្រទេសទាំងបីនៅមានកម្រិត ដោយសារសេដ្ឋកិច្ចនៅមានទំហំតូច ទាំងក្នុងតំបន់ និងសកល។ ភាពប្រកួតប្រជែង កម្រិតអភិវឌ្ឍន៍ ភាពបើកទូលាយ សមត្ថភាពនវានុវត្តន៍ និងវិស័យឯកជន នៅមានភាពទន់ខ្សោយនៅឡើយ ដែលជាឧបសគ្គរាំងដល់ការសម្រេចបាននូវគម្រោងមួយចំនួន ក្នុងការតភ្ជាប់សេដ្ឋកិច្ចត្រីភាគី។

២. ហេដ្ឋារចនាសម្ព័ន្ធផ្នែកដឹកជញ្ជូន ពាណិជ្ជកម្ម និងថាមពលរបស់កម្ពុជា-ឡាវ-វៀតណាម នៅមិនទាន់គ្រប់គ្រាន់ និងមានភាពទន់ខ្សោយជារួម បង្កជាផលលំបាកនានាដល់កិច្ចសហប្រតិបត្តិការ និងការតភ្ជាប់នៅក្នុងវិស័យផ្សេងទៀត ជាពិសេស វិស័យទេសចរណ៍ ពាណិជ្ជកម្ម និងការតភ្ជាប់រវាងប្រជាជន និងប្រជាជន។

៣. កម្ពុជា-ឡាវ-វៀតណាម នៅតែមានភាពខុសគ្នាមួយចំនួន ជាឧទាហរណ៍ វិស័យឯកជននៅកម្ពុជាដើរតួនាទីសកម្មជាងវិស័យឯកជននៅឡាវ និងវៀតណាម។ ប្រទេសទាំងបីក៏នៅមានភាពខុសគ្នា លើកម្រិតនៃភាពបើកទូលាយ និងសមាហរណកម្មសកល និងផ្នត់គំនិតស្តីពីសមាហរណកម្មសកល។

៤. ការបង្កើនការប្រកួតប្រជែង និងឥទ្ធិពលរបស់ប្រទេសមហាអំណាចជាច្រើននៅក្នុងតំបន់អាស៊ាន បង្កឲ្យមានការជះឥទ្ធិពលអវិជ្ជមានមកលើទំនាក់ទំនងផ្ទៃក្នុងអាស៊ាន ជាពិសេសមកលើប្រទេសកម្ពុជា ឡាវ និង វៀតណាម ដែលឈានដល់ការកាត់បន្ថយតម្រូវការនៃការតភ្ជាប់សេដ្ឋកិច្ចក្នុងចំណោមប្រទេសទាំងបី។

៥. ប្រទេសទាំងបីសំបូរទៅដោយធនធានមនុស្ស និងតម្លៃពលកម្មទាប ប៉ុន្តែគុណវុឌ្ឍិធនធានមនុស្សនៅមិនទាន់ឆ្លើយតបតាមកម្រិត និងតម្រូវការ សម្រាប់កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច ការតភ្ជាប់ និងការធ្វើសមាហរណកម្មនាពេលអនាគត។

៦. ប្រទេសទាំងបីបានរងផលប៉ះពាល់ពីជម្លោះក្នុងតំបន់ជាបន្តបន្ទាប់ ដែលបានបន្សល់ទុកនូវគ្រាប់មីន និងយុទ្ធភណ្ឌមិនទាន់ផ្ទុះជាច្រើន។ ប្រទេសទាំងបី បានអះអាងសារជាថ្មីនូវការប្តេជ្ញាចិត្តរបស់ខ្លួន ក្នុងការពង្រឹងកិច្ចសហ-ប្រតិបត្តិការបន្ថែមទៀត ដើម្បីធានាឲ្យបាននូវ សន្តិសុខ សុវត្ថិភាព និងការបោសសម្អាតគ្រាប់មីន និងយុទ្ធភណ្ឌ មិន

ទាន់ផ្ទះ ដើម្បីគាំទ្រគម្រោងអភិវឌ្ឍន៍ទាំងអស់នៅក្នុងប្រទេសនីមួយៗ និងរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ចសង្គម ប្រកបដោយចីរភាព។

## III. បញ្ហាចម្បងនានាដែលត្រូវដោះស្រាយ

### ៣.១. ការតភ្ជាប់ស្ថាប័ន

១. ប្រទេសកម្ពុជា ឡាវ និងវៀតណាម នៅមានភាពខុសគ្នាមួយចំនួន ទាក់ទិននឹងយន្តការនៃកិច្ចសហប្រតិបត្តិការ និងបទប្បញ្ញត្តិច្បាប់វិនិយោគ ពាណិជ្ជកម្ម ហិរញ្ញវត្ថុ ធនាគារ ពន្ធដារ និងការងារ។ ជាឧទាហរណ៍ តម្លៃដឹកជញ្ជូន ឆ្លងកាត់ព្រំដែននៃប្រទេសទាំងបីនៅមានភាពខុសគ្នា និងខ្ពស់ជាងតម្លៃមធ្យមក្នុងតំបន់អាស៊ាន ដោយសារកង្វះ ខាតហេដ្ឋារចនាសម្ព័ន្ធ នីតិវិធីពាណិជ្ជកម្មនៅមានភាពស្មុគស្មាញ និងសេវាកម្មឡជីស្ទីកនៅមិនទាន់សមស្រប។ នៅក្នុងវិស័យវិនិយោគ នីតិវិធីនៅតែមានភាពស្មុគស្មាញ និងមិនទាន់មានសង្គតិភាព ជាពិសេសលើគោលនយោបាយ ដីធ្លី និងគោលនយោបាយសម្រាប់វិនិយោគិនបរទេស។ ដូច្នេះ ការដោះស្រាយភាពខុសគ្នារបស់ស្ថាប័នខាងលើដូច បានរៀបរាប់ នឹងត្រូវប្រើពេលវេលាយូរ។

២. កន្លងមក កិច្ចសហប្រតិបត្តិការក្នុងការតភ្ជាប់ស្ថាប័ន ហេដ្ឋារចនាសម្ព័ន្ធ និង រវាងប្រជាជននិងប្រជាជន ក្នុងតំបន់ ត្រីកោណ កម្ពុជា-ឡាវ-វៀតណាម នៅមិនទាន់ទទួលបានលទ្ធផលដូចការរំពឹងទុកនៅឡើយ។ ប្រការនេះបណ្តាល ឲ្យកាត់បន្ថយនូវទំនុកចិត្ត និងបង្កការលំបាកក្នុងការបង្កើតយន្តការសហប្រតិបត្តិការថ្មីៗ រវាងកម្ពុជា-ឡាវ-វៀតណាម។

៣. ថ្មីៗនេះ គំនិតផ្តួចផ្តើមក្នុងការតភ្ជាប់ផ្សេងៗគ្នាជាច្រើន ត្រូវបានអនុវត្តនៅក្នុងប្រទេសអាស៊ានជារួម និងជា ពិសេសនៅប្រទេសកម្ពុជា ឡាវ និងវៀតណាម។ ប៉ុន្តែ ការសម្រេចបានក្នុងពេលជាមួយគ្នា នូវកិច្ចព្រមព្រៀងភាពជា ដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយតំបន់ ( Regional Comprehensive Economic Partnership - RCEP ) ជាមួយការចូល រួមពីអាស៊ាន ក៏នឹងមានឥទ្ធិពលគួរឲ្យកត់សម្គាល់លើទំនាក់ទំនងកម្ពុជា-ឡាវ-វៀតណាម ក្នុងក្របខណ្ឌទ្វេភាគី និង ពហុភាគីផងដែរ។

៤. លើសពីនេះ យន្តការ និងកម្មវិធីកិច្ចសហប្រតិបត្តិការត្រីភាគីរបស់កម្ពុជា-ឡាវ-វៀតណាម នៅតែមានកម្រិតនៅ ឡើយ។ កិច្ចសហប្រតិបត្តិការនាឆ្នាំកន្លងមកនេះ មានលក្ខណៈជាកិច្ចសហប្រតិបត្តិការទ្វេភាគី ក្នុងចំណោមកម្ពុជា ឡាវ និងវៀតណាម។

### ៣.២. ការតភ្ជាប់ហេដ្ឋារចនាសម្ព័ន្ធ និងសេដ្ឋកិច្ច

១. ទស្សនៈ និងធនធាននានាសម្រាប់កិច្ចសហប្រតិបត្តិការ និងការតភ្ជាប់រវាងប្រទេសកម្ពុជា-ឡាវ-វៀតណាម ភាគច្រើនកើតចេញពីរដ្ឋាភិបាលនៃប្រទេសទាំងបី។ ការចូលរួមពីវិស័យឯកជនទាក់ទងនឹងទស្សនៈ និងធនធាន នៅមានកម្រិត និងមិនទាន់មានប្រសិទ្ធភាពនៅឡើយ។

២. ការតភ្ជាប់ហេដ្ឋារចនាសម្ព័ន្ធរវាងប្រទេសទាំងបី ពិសេសហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន ពាណិជ្ជកម្ម និងថាមពល នៅតែប្រឈមនឹងការលំបាកជាច្រើន ហើយនៅមិនទាន់គ្រប់គ្រាន់ឆ្លើយតបទៅនឹងតម្រូវការ។ កត្តាទាំងនេះបាន

កាត់បន្ថយការប្រកួតប្រជែងរបស់ប្រទេសទាំងបី និងរឹតត្បិតការតភ្ជាប់នៅក្នុងវិស័យពាក់ព័ន្ធផ្សេងទៀត ជាក់ស្តែងក្នុងវិស័យទេសចរណ៍ ពាណិជ្ជកម្ម និងការតភ្ជាប់រវាងប្រជាជននិងប្រជាជន។ នេះជាភាពទន់ខ្សោយដែលពិបាកក្នុងការដោះស្រាយ ពីព្រោះការធ្វើទំនើបភាវូបនីយកម្ម និងការកសាងប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធស្របគ្នាទាមទារពេលវេលា និងធនធានច្រើន។

៣.ជាក់ស្តែង កិច្ចសហប្រតិបត្តិការ និងការតភ្ជាប់សេដ្ឋកិច្ចរវាងប្រទេសកម្ពុជា-ឡាវ-វៀតណាម កន្លងមក បង្ហាញអំពីកង្វះស័ក្តិសិទ្ធភាពក្នុងគម្រោង និងតាមវិស័យនៃកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចទាំងក្របខណ្ឌទ្វេភាគី និងត្រីភាគី។ កត្តានេះអាចកាត់បន្ថយទំនុកចិត្តសម្រាប់កិច្ចសហប្រតិបត្តិការ នាពេលខាងមុខ។

### ៣.៣. ការតភ្ជាប់រវាងប្រជាជន និងប្រជាជន

១. ឧបសគ្គនានា នៅតែកើតមានចំពោះនីតិវិធី និងបទប្បញ្ញត្តិឆ្លងកាត់ព្រំដែននៃប្រទេសទាំងបី ដូចជានីតិវិធីផ្តល់ទិដ្ឋាការ ការចុះបញ្ជីនិយោជិក នីតិវិធីគយ និងភាពរាំងស្ទះដល់ការផ្លាស់ប្តូរ និងកិច្ចសហប្រតិបត្តិការរបស់ប្រជាជន ក៏ដូចជាលំហូរនៃទំនិញនិងប្រជាជនឆ្លងកាត់ព្រំដែន។

២. ហិរញ្ញប្បទានសម្រាប់សកម្មភាពតភ្ជាប់រវាងប្រជាជន និងប្រជាជននៅមានកម្រិតនៅឡើយ ក្នុងប្រទេសទាំងបី កម្ពុជា-ឡាវ-វៀតណាម ដែលជាប្រទេសក្រីក្រ ពិសេសបណ្តាខេត្តជាប់ព្រំដែនរបស់ប្រទេសទាំងបី ជាខេត្តក្រីក្របំផុត។

៣. មិនទាន់មានគម្រោងរយៈពេលវែង ដែលមានលក្ខណៈជាយុទ្ធសាស្ត្រសំខាន់សម្រាប់ការតភ្ជាប់រវាងប្រជាជន និងប្រជាជន ដែលមិនអាចទាក់ទាញបាននូវការចូលរួមពីសហគមន៍ធុរកិច្ច ជាក់ស្តែងការចូលរួមពីវិស័យឯកជន និងការគាំទ្រយ៉ាងសកម្មពីដៃគូ និងអង្គការអន្តរជាតិនានាផងដែរ។

# ផ្នែកទី ២
# ទស្សនៈ គោលបំណង និងមាតិកា នៃការតភ្ជាប់សេដ្ឋកិច្ចប្រទេសទាំងបី

## I. ទស្សនៈ

១. នៅក្នុងផែនការសកម្មភាពនេះ គោលគំនិតនៃ "ការតភ្ជាប់សេដ្ឋកិច្ច" សំដៅលើការបង្កើនការសម្របសម្រួល ដើម្បីកំណត់រកភាពខុសគ្នា និងឧបសគ្គនានា បង្កើតភាពស្របគ្នា និងភាពរលូន ក្នុងកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច កម្ពុជា-ឡាវ-វៀតណាម នៅក្នុងវិស័យចម្បងៗ ដូចជាស្ថាប័ន ហេដ្ឋារចនាសម្ព័ន្ធ និងការតភ្ជាប់រវាងប្រជាជននិងប្រជាជន។

២.ការតភ្ជាប់សេដ្ឋកិច្ចកម្ពុជា-ឡាវ-វៀតណាម ត្រូវផ្អែកលើគោលការណ៍នៃការគោរពគ្នាទៅវិញទៅមកលើឯករាជ្យភាព អធិបតេយ្យភាព និងបូរណភាពទឹកដី ព្រមទាំងការគាំទ្រ និងកិច្ចសម្របសម្រួលដល់ការអភិវឌ្ឍទៅវិញទៅមក ដើម្បីសម្រេចបាននូវការមូលមតិជាឯកច្ឆ័ន្ទ រវាងរដ្ឋាភិបាល និងប្រជាជននៃប្រទេសទាំងបី។

៣. មាតិកានៃការតភ្ជាប់សេដ្ឋកិច្ចកម្ពុជា-ឡាវ-វៀតណាម ត្រូវមានភាពស្របគ្នាជាមួយនឹងការអនុវត្តជាលក្ខណៈអន្តរជាតិ និងកាតព្វកិច្ចក្នុងកិច្ចសហប្រតិបត្តិការទ្វេភាគី ជាពិសេសក្នុងតំបន់អាស៊ាន ព្រមទាំងច្បាប់ និងបទប្បញ្ញត្តិរបស់ប្រទេសនីមួយៗ។

៤. ការតភ្ជាប់សេដ្ឋកិច្ចកម្ពុជា-ឡាវ-វៀតណាម ត្រូវផ្អែកលើគោលការណ៍នៃភាពដែលអាចធ្វើបាន ដោយផ្តោតលើវិស័យអាទិភាពដែលមានសក្តានុពល និងគុណសម្បត្តិដែលអាចបំពេញឲ្យគ្នាទៅវិញទៅមកប្រកបដោយប្រសិទ្ធភាព។ សារៈសំខាន់ដ៏ធំធេងត្រូវផ្សារភ្ជាប់ទៅនឹងផលប្រយោជន៍រួម យុទ្ធសាស្ត្រសមាហរណកម្ម និងការអភិវឌ្ឍរយៈពេលវែងរបស់ប្រទេសទាំងបី។

៥. ការតភ្ជាប់សេដ្ឋកិច្ចកម្ពុជា-ឡាវ-វៀតណាម ត្រូវសម្រេចឲ្យបានលឿន និងកាន់តែស៊ីជម្រៅប្រកបដោយគុណភាពខ្ពស់ជាងកាតព្វកិច្ចក្នុងការតភ្ជាប់របស់ប្រទេសទាំងបីក្រោមក្របខណ្ឌសហគមន៍អាស៊ាន។

## II. គោលបំណង

១. បង្កើតហេដ្ឋារចនាសម្ព័ន្ធដែលមានភាពអំណោយផល ភាពច្បាស់លាស់ផ្នែកស្ថាប័ន វប្បធម៌ ទេសចរណ៍ និងការយោគយល់គ្នារវាងប្រជាជនក្នុងប្រទេសទាំងបី សំដៅពង្រឹង និងធ្វើទំនើបកម្មការតភ្ជាប់ហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន កសិកម្ម ថាមពល និងការទំនាក់ទំនងជាបន្តបន្ទាប់ ជំរុញឲ្យមានសាមញ្ញភាព នៅក្នុងដំណើរការ និងនីតិវិធីដើម្បីសម្រួលចរាចរណ៍ទំនិញ និងមនុស្សឆ្លងកាត់ព្រំដែនឲ្យកាន់តែងាយស្រួល ស្របតាមច្បាប់ និងបទប្បញ្ញត្តិរបស់ប្រទេសនីមួយៗ និងលើកកម្ពស់ការដោះដូរ និងការយោគយល់រវាងប្រជាជននៃប្រទេសទាំងបី។

២. តភ្ជាប់សេដ្ឋកិច្ចនៃប្រទេសទាំងបី សំដៅជំរុញកិច្ចសហប្រតិបត្តិការ សន្តិភាព មិត្តភាព និងទំនាក់ទំនងប្រកបដោយអត្ថប្រយោជន៍ទៅវិញទៅមក ដើម្បីភាពសម្បូររុងរឿងនៃប្រទេសទាំងបី។

៣. ការតភ្ជាប់សេដ្ឋកិច្ចនឹងក្លាយជាកម្លាំងចលករក្នុងការអភិវឌ្ឍសេដ្ឋកិច្ច-សង្គម នៅក្នុងប្រទេសនីមួយៗ ក៏ដូចជាមូលដ្ឋានគ្រឹះសម្រាប់ប្រទេសទាំងបី ដើម្បីធ្វើសមាហរណកម្មទៅក្នុងសហគមន៍អាស៊ាន ពិសេសសហគមន៍សេដ្ឋកិច្ចអាស៊ាន និងសម្រាប់ធ្វើសមាហរណកម្មថ្នាក់តំបន់ និងសកល ឲ្យកាន់តែស៊ីជម្រៅ និងស័ក្តិសិទ្ធភាពជាងមុន។

## III. មាតិកានៃការតភ្ជាប់

**១.ការតភ្ជាប់ស្ថាប័ន** រួមមានការបង្កើនទំនាក់ទំនងគោលនយោបាយ និងការផ្លាស់ប្តូរព័ត៌មានក្នុងចំណោមប្រទេសទាំងបី ការសម្របសម្រួលក្នុងការអភិវឌ្ឍ និងអនុវត្តគោលនយោបាយម៉ាក្រូ ការពន្លឿនបន្ថែមទៀតលើការអនុវត្តនីតិវិធីគយនិងកិច្ចសម្រួលពាណិជ្ជកម្មនៅក្នុងអាស៊ាន និងតារាងកាត់បន្ថយពន្ធនៅក្នុងកិច្ចព្រមព្រៀងពាណិជ្ជកម្មទំនិញអាស៊ាន ( ASEAN Trade in Goods Agreement - ATIGA ) ដែលនឹងលុបបំបាត់ឧបសគ្គជាបទប្បញ្ញត្តិដែលរាំងស្ទះដល់កិច្ចសហប្រតិបត្តិការក្នុងការធ្វើសាមញ្ញភាពលើនីតិវិធី ដើម្បីជំរុញការវិនិយោគ ពាណិជ្ជកម្ម ទេសចរណ៍ កសិកម្ម ការដឹកជញ្ជូន ការបណ្តុះបណ្តាល/អភិវឌ្ឍនិងការគ្រប់គ្រងធនធានមនុស្ស សំដៅបង្កើតឲ្យមានបរិយាកាសអំណោយផលដល់ប្រជាពលរដ្ឋ និងអាជីវកម្មរបស់ប្រទេសទាំងបី ក្នុងការសហការដើម្បីផ្តល់ផលប្រយោជន៍ឲ្យគ្នាទៅវិញទៅមក។

**២.ការតភ្ជាប់ហេដ្ឋារចនាសម្ព័ន្ធ** ផ្តោតលើការបង្កើនកម្រិត ការធ្វើទំនើបកម្ម និងការធានាឲ្យមានការតភ្ជាប់កាន់តែងាយស្រួល និងរលូននូវហេដ្ឋារចនាសម្ព័ន្ធលើវិស័យដឹកជញ្ជូន ព័ត៌មាននិងទូរគមនាគមន៍ ថាមពល ពាណិជ្ជកម្ម កសិកម្ម និងទេសចរណ៍របស់ប្រទេសទាំងបី។

**៣.ការតភ្ជាប់រវាងប្រជាជន និងប្រជាជន** រួមមាន ការតភ្ជាប់នៅក្នុងវិស័យអប់រំ សុខាភិបាល វប្បធម៌ កីឡា ទេសចរណ៍ សហគ្រិនភាព សកម្មភាពមនុស្សធម៌ ការបណ្តុះបណ្តាល/អភិវឌ្ឍនិងការគ្រប់គ្រងធនធានមនុស្ស សំដៅបង្កើនការផ្លាស់ប្តូរទស្សនកិច្ចប្រជាជន និងសកម្មភាពទីក្រុងសម្ព័ន្ធភាព រវាងថ្នាក់ងារមូលដ្ឋាន និងអង្គការនានា នៃប្រទេសទាំងបី។ កំណែទម្រង់ស្ថាប័នត្រូវបានជំរុញយ៉ាងសកម្ម ដើម្បីលុបបំបាត់ឧបសគ្គដែលរាំងស្ទះដល់ចរាចរណ៍ប្រជាជនឆ្លងកាត់ព្រំដែន ព្រមទាំងសម្របសម្រួលកិច្ចសហប្រតិបត្តិការលើវិស័យខាងលើ។

# ផ្នែកទី ៣

# យុទ្ធសាស្ត្រសំខាន់ៗសម្រាប់បង្កើន ការតភ្ជាប់សេដ្ឋកិច្ចកម្ពុជា-ឡាវ-វៀតណាម

## I. ការតភ្ជាប់ស្ថាប័ន

១. បង្កើនទំនាក់ទំនង និងការចែករំលែកព័ត៌មានគោលនយោបាយទៅវិញទៅមក ក្នុងចំណោមប្រទេសទាំងបី រួមមានទិសដៅយុទ្ធសាស្ត្រអភិវឌ្ឍន៍ ទិសដៅម៉ាក្រូសេដ្ឋកិច្ច និងទិសដៅសមាហរណកម្មសកល។ សម្របសម្រួលរៀបចំ ផែនការមេអភិវឌ្ឍន៍រយៈពេលមធ្យមនិងវែង និងផែនការនានារបស់ប្រទេសទាំងបី ព្រមទាំងរៀបចំទិន្នន័យស្ថិតិរួមក្នុងវិស័យសេដ្ឋកិច្ច-សង្គម និងបរិស្ថាន។ បង្កើនការផ្លាស់ប្តូរយ៉ាងសកម្ម នូវព័ត៌មានគោលនយោបាយនៅក្នុងវិស័យ ពាក់ព័ន្ធនឹងការវិនិយោគ ពាណិជ្ជកម្ម ពន្ធដារ ពន្ធគយ និងស្ថិតិ។

២. បង្កើនការផ្លាស់ប្តូរបទពិសោធន៍ និងការសម្របសម្រួលក្នុងការអភិវឌ្ឍនិងការអនុវត្តគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច ក្នុងនោះមានដូចជា បទពិសោធន៍ក្នុងការធ្វើឲ្យមានស្ថិរភាពនៃអត្រាប្តូរប្រាក់ក្នុងស្រុក ការគ្រប់គ្រងអតិផរណា ព្រមទាំងលើកកម្ពស់កិច្ចសហប្រតិបត្តិការជាមួយស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ ក្នុងការទប់ស្កាត់ហានិភ័យផ្នែកហិរញ្ញវត្ថុ និងរូបិយវត្ថុ។ បង្កើនការផ្លាស់ប្តូរបទពិសោធន៍ក្នុងការគណនាផលិតផលក្នុងស្រុកសរុប (GDP) និងផលិតផលក្នុងស្រុកតំបន់សរុប (GRDP)។

៣. បង្កើតបរិយាកាស និងក្របខណ្ឌគោលនយោបាយប្រកបដោយភាពអំណោយផល ដើម្បីជំរុញសកម្មភាពវិនិយោគ និងពាណិជ្ជកម្ម ជួយដល់ប្រទេសទាំងបីក្នុងការដោះស្រាយបញ្ហានានា ពន្លឿនការអនុវត្តគម្រោងដែលទទួលបានអាជ្ញាប័ណ្ណ ផ្តល់ការណែនាំលើក្របខណ្ឌនិងវិស័យនៃកិច្ចសហប្រតិបត្តិការវិនិយោគដល់ថ្នាក់មូលដ្ឋាន និងអាជីវកម្មទាំងឡាយ។ ដូច្នេះ កម្ពុជា និងវៀតណាមគួរបញ្ចប់ការចរចាកិច្ចព្រមព្រៀងស្តីពីការចៀសវាងការយកពន្ធត្រួតគ្នាឲ្យបានឆាប់តាមលទ្ធភាពដែលអាចធ្វើបាន។ ចំពោះវិស័យពាណិជ្ជកម្ម ភាគីទាំងបីបានបញ្ចប់ការចរចាលើកិច្ចព្រមព្រៀងស្តីពីការជំរុញ និងសម្រួលពាណិជ្ជកម្មតំបន់ត្រីកោណអភិវឌ្ឍន៍ កម្ពុជា-ឡាវ-វៀតណាម ដែលបានចុះហត្ថលេខានៅខែវិច្ឆិកា ឆ្នាំ២០១៦ រួចមកហើយ។

៤. ពង្រឹងការកែទម្រង់នីតិវិធីរដ្ឋបាលពាក់ព័ន្ធនឹងការវិនិយោគ និងធុរកិច្ច សំដៅទៅរកភាពងាយស្រួល ភាពស៊ីសង្វាក់ ការផ្សព្វផ្សាយដល់សាធារណជន តម្លាភាព និងសង្គតិភាពនៅក្នុងប្រទេសនីមួយៗ ដែលកាត់បន្ថយផលលំបាក និងបញ្ហានានាសម្រាប់ធុរកិច្ច។ សម្រាប់រយៈពេលវែង ការសិក្សាគួរតែត្រូវបានធ្វើឡើង ដើម្បីឈានដល់ការ

ឯកភាពលើបទប្បញ្ញត្តិ និងគោលនយោបាយរួមរវាងប្រទេសទាំងបី ដូចជាគោលនយោបាយលើកទឹកចិត្តការវិនិយោគ គោលនយោបាយកិច្ចសម្រួលពាណិជ្ជកម្ម ការលើកទឹកចិត្តផ្នែកពន្ធដារ និងការជ្រើសរើសពលករសម្រាប់អាជីវកម្មរបស់ប្រទេសកម្ពុជា-ឡាវ-វៀតណាម។

៥. ពន្លឿនបន្ថែមទៀតនូវការអនុវត្តបទដ្ឋានអន្តរជាតិនៃនីតិវិធីគយ ដែលត្រូវបានឯកភាពអនុវត្តស្របតាមក្របខណ្ឌអាស៊ាន ឆ្លើយតបតាមស្មារតីនៃផែនការមេស្តីពីការតភ្ជាប់អាស៊ាន ២០២៥ (MPAC 2025)។

## II. ការតភ្ជាប់ហេដ្ឋារចនាសម្ព័ន្ធ និងការតភ្ជាប់វិស័យសេដ្ឋកិច្ចសំខាន់ៗដែលបានកំណត់

### ២.១. ហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន

១. សាងសង់ ជួសជុល និងតម្លើងកម្រិតផ្លូវឆ្លងកាត់ដើម្បីតភ្ជាប់ប្រទេសទាំងបី ឲ្យស្របតាមបទដ្ឋានអប្បបរមាកម្រិត៣ របស់អាស៊ាន, រៀបចំសិក្សាតាមការចាំបាច់នានា លើការសាងសង់ផ្លូវកាត់តភ្ជាប់រាជធានី/រដ្ឋធានីនៃប្រទេសទាំងបី, ជានាឲ្យមានផ្លូវតភ្ជាប់ទៅវិញទៅមករវាងបណ្តាខេត្តតាមព្រំដែននីមួយៗនៃប្រទេសទាំងបី, និងរៀបចំសិក្សារួមគ្នាលើលទ្ធភាពកសាងផ្លូវល្បឿនលឿនតភ្ជាប់ប្រទេសទាំងបី ជាពិសេសសម្រាប់ការតភ្ជាប់មជ្ឈមណ្ឌល/តំបន់សេដ្ឋកិច្ច និងទេសចរណ៍។

២. ប្រទេសទាំងបីកម្ពុជា-ឡាវ-វៀតណាម ត្រូវវិនិយោគលើការតម្លើងកម្រិតផ្លូវថ្នល់ ដូចបានកំណត់ក្នុងក្របខណ្ឌអាស៊ាន និងកិច្ចសហប្រតិបត្តិការមហាអនុតំបន់មេគង្គឲ្យបានយ៉ាងតិចត្រឹមកម្រិត៣ នៃបទដ្ឋានអាស៊ាន។ ប្រទេសទាំងបីរួមគ្នាស្តារឡើងវិញ ព្រមទាំងតម្លើងផ្លូវជនបទ និងផ្លូវជាតិភ្ជាប់ទៅនឹងច្រកព្រំដែនអន្តរជាតិ និងច្រកសំខាន់ៗផ្អែកលើលទ្ធភាពផ្នែកហិរញ្ញវត្ថុនៃប្រទេសនីមួយៗ។

៣. បញ្ចប់ការសិក្សានានា លើការបង្កើតផែនការមេរួម សម្រាប់បណ្តាញផ្លូវល្បឿនលឿន កម្ពុជា-ឡាវ-វៀតណាម ដើម្បីជានាឲ្យមានសង្គតិភាពក្នុងប្រទេសទាំងបី និង រវាងប្រទេសទាំងបីនិងតំបន់អាស៊ាន។

៤. ធ្វើការសិក្សាស្រាវជ្រាវ សម្រាប់អនុវត្តគម្រោងការដឹកជញ្ជូនមួយចំនួន ក្នុងការតភ្ជាប់ប្រទេសទាំងបីដែលមានដូចខាងក្រោមៈ

- ផ្លូវល្បឿនលឿនតភ្ជាប់ឡាវ និងវៀតណាម ដែលចេញពីទីក្រុងវៀងចន្ទ ឆ្លងកាត់ច្រកព្រំដែនប៉ាក់សានទៅថាញ់ហ្វី (ខេត្តហ្ស៊ិអាន វៀតណាម) ហើយភ្ជាប់ទៅផ្លូវល្បឿនលឿនភាគខាងជើង-ត្បូង (វៀតណាម)
- ផ្លូវល្បឿនលឿនតភ្ជាប់ពីកម្ពុជាទៅភាគខាងត្បូងវៀតណាម ចេញពីភ្នំពេញ (កម្ពុជា) ទៅ កាយមិប-ធិវ៉ៃ (វៀតណាម)

- ផ្លូវល្បឿនលឿន តភ្ជាប់ឡាវ និងកម្ពុជា ចេញពីទីក្រុងវៀងចន្ទ ឆ្លងកាត់ផ្លូវជាតិលេខ១៣ ទៅភ្នំពេញ (កម្ពុជា) ដែលស្ថិតនៅក្រោមគម្រោង AH លេខ១១ របស់អាស៊ាន។

-ផ្លូវល្បឿនលឿន តភ្ជាប់ខេត្តត្រាត របស់ថៃ ឆ្លងកាត់ផ្លូវជាតិ លេខ៤៨ លេខ៤ លេខ៣ និងលេខ៣៣ របស់កម្ពុជានៃច្រករបៀងផ្លូវសមុទ្រខាងត្បូង ទៅកាន់ច្រកព្រំដែន សាសៀ ខេត្តហាទៀង របស់វៀតណាម។

៥. ប្រទេសទាំងបី កម្ពុជា-ឡាវ-វៀតណាម សម្របសម្រួលរៀបចំសិក្សាស្រាវជ្រាវលើការអភិវឌ្ឍផ្លូវរថភ្លើងតភ្ជាប់ក្រោមក្របខណ្ឌគម្រោងរថភ្លើងសិង្ហបុរី-គុនមីញ (SKRL) ស្របតាមកាតព្វកិច្ចដែលបានធ្វើឡើងក្នុងផែនការមេស្តីពីការតភ្ជាប់អាស៊ាន ២០២៥ (MPAC) រួមមាន៖

- ផ្លូវរថភ្លើងទីក្រុងហូជីមិញ - ឡុកនីញ (វៀតណាម) - ភ្នំពេញ (កម្ពុជា) ដែលមានចំណុចតភ្ជាប់ផ្លូវរថភ្លើងជាមួយកម្ពុជា នៅច្រកព្រំដែនហ័រលូ / ច្រកត្រពាំងស្រែ។

- ផ្លូវរថភ្លើងទីក្រុងវៀងចន្ទ (ឡាវ) – វុងអាង (វៀតណាម)។

៦. កម្ពុជា ឡាវ និងវៀតណាម រួមគ្នាអនុវត្តផែនការមេស្តីពីការអភិវឌ្ឍប្រព័ន្ធផ្លូវទឹកក្នុងអាស៊ាន ព្រមទាំងសម្របសម្រួលជាមួយគ្នា ដើម្បីរៀបចំសិក្សាការស្តារប្រព័ន្ធផ្លូវទឹកខាងក្នុង ឆ្ពោះទៅកាន់ច្រកផ្លូវទឹកអន្តរជាតិ និងច្រកព្រំដែនសំខាន់ៗ សាងសង់កំពង់ផែទន្លេ និងស្ថានីយ៍ ដើម្បីឆ្លើយតបទៅនឹងតម្រូវការសម្រាប់ការចតនាវាឆ្លងកាត់ទន្លេ ការដឹក និងលើកដាក់ទំនិញ និងដាក់ស្ថានីយ៍ឆ្លងកាត់ទន្លេឲ្យប្រតិបត្តិការជាផ្លូវការ ដោយអនុលោមទៅតាមច្បាប់ និងបទប្បញ្ញត្តិនៃប្រទេសនីមួយៗ។

៧. អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធកំពង់ផែសមុទ្រដែលសមស្រប និងទំនើបនៅកម្ពុជា និងវៀតណាមរៀងៗខ្លួន ផ្អែកលើផែនការមេ ស្តីពីការតភ្ជាប់អាស៊ាន ២០២៥ (MPAC 2025) សំដៅបង្កើនសមត្ថភាពនៃប្រព័ន្ធកំពង់ផែសមុទ្រអាស៊ាន (កំពង់ផែសមុទ្រចំនួន ៤៧ ដូចបានសន្យាដោយរដ្ឋសមាជិកអាស៊ាន) កែលម្អសេវាកម្មពាក់ព័ន្ធ ដូចជាឃ្លាំងស្តុក និងប្រព័ន្ធបូមកាកសំណល់ តាមការចាំបាច់ និងពង្រឹងការតភ្ជាប់ជាមួយនឹងផ្លូវសកល និងតំបន់សំខាន់ៗ រួមទាំងផ្លូវដឹកជញ្ជូនតាមសមុទ្រ នៅក្នុងប្រទេសនីមួយៗ។

៨. វៀតណាមគួរតែកែលម្អគុណភាពប្រព័ន្ធឡូជីស្ទីក និងបង្កើតលក្ខខណ្ឌអំណោយផលនានាសម្រាប់ឡាវក្នុងការប្រើប្រាស់កំពង់ផែសមុទ្ររបស់វៀតណាម ប្រើប្រាស់និងឲ្យជួលឃ្លាំងស្តុកទំនិញនៅកំពង់ផែវុងអាង កំពង់ផែសួនហាយ និងកំពង់ផែហុនឡា (វៀតណាម) សម្រាប់នាំចូល និងនាំចេញទំនិញរបស់ខ្លួន។

៩.ស្តារ និងតម្លើងប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធ សម្រាប់បង្កើនប្រសិទ្ធភាពប្រតិបត្តិការនៃព្រលានយន្តហោះ ដែលមានស្រាប់ដើម្បីបង្កើនការតភ្ជាប់តាមផ្លូវអាកាសនៃប្រទេសទាំងបី, រួមគ្នាអភិវឌ្ឍន៍ផ្លូវអាកាសដើម្បីសន្សំពេលវេលាហោះហើរ និងសន្សំសំចៃថ្លៃចំណាយប្រេងឥន្ធនៈ, ពង្រឹងកិច្ចសហប្រតិបត្តិការ សំដៅជានាប្រតិបត្តិការ សន្តិសុខ និងសុវត្ថិភាពហោះហើរ សម្រាប់អាកាសចរណ៍កម្ពុជា ឡាវ និងវៀតណាម។

១០. ផ្តោតសំខាន់លើការធ្វើពិពិធកម្ម និងទាញយកប្រភពមូលនិធិ ដើម្បីអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន។

## ២.២. ហេដ្ឋារចនាសម្ព័ន្ធថាមពល

១. វិនិយោគលើការសាងសង់បណ្តាញបញ្ជូនថាមពល សម្រាប់តភ្ជាប់ប្រទេសទាំងបីស្របតាមវឌ្ឍនភាពនៃការសាងសង់គម្រោងផលិតថាមពល ដើម្បីជានាការផ្គត់ផ្គង់ថាមពលសម្រាប់ផលិតកម្ម និងការប្រើប្រាស់នៅក្នុងប្រទេសទាំងបី ។

២. ដោះស្រាយជាបន្ទាន់នូវបញ្ហានានា ដូចជាដើមទុន ការបោសសំអាតទីតាំង ដើម្បីពន្លឿនការផ្តល់អាជ្ញាប័ណ្ណដល់គម្រោងវារីអគ្គិសនីតាមផែនការ ដោះស្រាយកង្វះខាតនានា ពង្រឹងការគ្រប់គ្រងដើម្បីជានានូវគុណភាពគម្រោង និងតាមកាលវិភាគនៃការអនុវត្ត។ យកចិត្តទុកដាក់លើការអភិវឌ្ឍតំបន់តាំងទីលំនៅថ្មី ដើម្បីជានាជីវភាពសមរម្យដល់ប្រជាជនដែលបានបម្លាស់ទីពីតំបន់នៃគម្រោង។

៣. លើកទឹកចិត្តឲ្យមានគម្រោងវិនិយោគក្នុងវិស័យថាមពលស្អាត និងកកើតឡើងវិញ ជាពិសេសនៅតំបន់ព្រំដែនកម្ពុជា ឡាវ និងវៀតណាម ដើម្បីជានាការផ្គត់ផ្គង់ថាមពល ដែលឆ្លើយតបទៅនឹងតម្រូវការនៅតំបន់ដាច់ស្រយាលនៃប្រទេសនីមួយៗ។

៤. បន្តអនុវត្តពាណិជ្ជកម្មថាមពលរវាងអាជ្ញាធរមូលដ្ឋានតំបន់ព្រំដែននៃប្រទេសទាំងបី លើទីតាំងដែលបានឯកភាព និងទីតាំងដែលនឹងត្រូវពង្រីកបន្ថែម។ វៀតណាម នឹងផ្តោតសំខាន់លើការសហការជាមួយឡាវ លើការធ្វើពាណិជ្ជកម្មថាមពល ដើម្បីបំពេញគម្លាតថាមពលអគ្គិសនី។

៥. ជំរុញ និងសម្របសម្រួលការអនុវត្តប្រព័ន្ធថាមពលរួមបញ្ចូលគ្នារបស់ប្រទេសទាំងបី ដើម្បីជានានូវការតភ្ជាប់ថាមពលប្រកបដោយសុវត្ថិភាព និងស្ថិរភាព។

## ២.៣. ប្រៃសណីយ៍ និងទូរគមនាគមន៍

១. សហការយ៉ាងសកម្មក្នុងការផ្លាស់ប្តូរបទពិសោធន៍ ការអនុវត្ត និងការសម្រួលគោលនយោបាយកិច្ចសហប្រតិបត្តិការ និងយន្តការផ្សេងៗទៀតក្នុងវិស័យប្រៃសណីយ៍ ទូរគមនាគមន៍ និងបច្ចេកវិទ្យាព័ត៌មានវិទ្យានិងទូរគមនាគមន៍ (ICT) ដើម្បីឆ្ពោះទៅរកសាមញ្ញភាព និងភាពងាយស្រួល។

២. ជំរុញកិច្ចសហប្រតិបត្តិការក្នុងការកសាងហេដ្ឋារចនាសម្ព័ន្ធ សម្រាប់វិស័យប្រៃសណីយ៍ និងទូរគមនាគមន៍នៃប្រទេសទាំងបី។ លើកទឹកចិត្តក្នុងការពង្រីកវិស័យហេដ្ឋារចនាសម្ព័ន្ធទូរគមនាគមន៍ និងបណ្តាញប្រៃសណីយ៍រហូតដល់មណ្ឌលគ្រប់គ្រងរដ្ឋបាលស្រុក និងឃុំនៃប្រទេសកម្ពុជា ឡាវ និងវៀតណាម។

៣. លើកទឹកចិត្តឲ្យមានការផ្លាស់ប្តូរបទពិសោធន៍ក្នុងការបង្កើត និងអភិវឌ្ឍឧស្សាហកម្មប្រៃសណីយ៍និងទូរគមនាគមន៍។ បង្កើនកិច្ចសហប្រតិបត្តិការ ក្នុងការកសាងសមត្ថភាពក្នុងវិស័យប្រៃសណីយ៍ទូរគមនាគមន៍ និងបច្ចេកវិទ្យាព័ត៌មានវិទ្យា និងទូរគមនាគមន៍ (ICT) ជាពិសេសនៅក្នុងប្រទេសកម្ពុជា និងឡាវ។

៤. ជំរុញកិច្ចសហប្រតិបត្តិការត្រីភាគី ក្នុងវិស័យបណ្តាញសន្តិសុខ និងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធព័ត៌មាន។ ទន្ទឹមនឹងនោះដែរ ការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានវិទ្យានិងទូរគមនាគមន៍ ត្រូវទទួលបានការសម្របសម្រួលដើម្បីលើកកម្ពស់កិច្ចសហប្រតិបត្តិការលើវិស័យផ្សេងៗទៀត ដូចជា គយ ពាណិជ្ជកម្ម (រួមទាំងពាណិជ្ជកម្មអេឡិចត្រូនិក) ទេសចរណ៍ ហិរញ្ញវត្ថុ និងធនាគារជាដើម។

## ២.៤ វិនិយោគ

១. អាជ្ញាធរពាក់ព័ន្ធនៃប្រទេសទាំងបី ត្រូវសម្របសម្រួលឲ្យបានជិតស្និទ្ធ លើបញ្ហាពាក់ព័ន្ធនឹងការមិនផ្តល់អាជ្ញាប័ណ្ណដល់ការវិនិយោគ និងគាំទ្រការពន្លឿនការអនុវត្តគម្រោងវិនិយោគខ្នាតធំ ជាពិសេសក្នុងក្របខណ្ឌកិច្ចសហប្រតិបត្តិការនៃរដ្ឋាភិបាលទាំងបី និងក្រសួង-ស្ថាប័នពាក់ព័ន្ធនៃប្រទេសទាំងបី។ ទន្ទឹមនឹងនោះដែរ ការផ្លាស់ប្តូរព័ត៌មានដោយភាគីពាក់ព័ន្ធក្នុងដំណើរការពិនិត្យ និងការផ្តល់អាជ្ញាប័ណ្ណដល់គម្រោងវិនិយោគខ្នាតធំ គួរតែត្រូវបានលើកកម្ពស់ឲ្យបានខ្លាំង ដើម្បីធានាការអនុវត្តដោយរលូន និងដោះស្រាយបញ្ហានានាឲ្យបានទាន់ពេលវេលា។

២. ត្រូវសិក្សារួមគ្នាលើលទ្ធភាពនៃការបង្កើតគោលនយោបាយ និងយន្តការរួមស្តីពីការអនុគ្រោះលើវិស័យវិនិយោគ និងរៀបចំកម្មវិធីលើកកម្ពស់ការវិនិយោគ ដើម្បីអំពាវនាវដល់ការវិនិយោគរបស់ដៃគូអន្តរជាតិនៅក្នុងប្រទេសទាំងបី ធ្វើពិពិធកម្មលើប្រភេទនៃការវិនិយោគសម្រាប់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ជាពិសេសការវិនិយោគក្នុងទម្រង់ភាពជាដៃគូរដ្ឋ-ឯកជន (Public-Private Partnership - PPP)។

៣. រៀបចំប្រព័ន្ធផែនការមេ ដើម្បីការអភិវឌ្ឍតាមវិស័យនិងតាមតំបន់ កសាងជីកសិកម្ម ដីព្រៃ និងការប្រើប្រាស់ ដីលំនៅស្ថានរបស់ប្រទេសនីមួយៗ ដើម្បីបង្កើតជាមូលដ្ឋានរឹងមាំក្នុងការទាក់ទាញការវិនិយោគបរទេសលើគម្រោងដែលបានបញ្ចូលក្នុងផែនការមេ។

## ២.៥. ពាណិជ្ជកម្ម និងបញ្ហាទាក់ទងនឹងពាណិជ្ជកម្ម

១. ដើម្បីបង្កើនទំហំពាណិជ្ជកម្មក្នុងប្រទេសទាំងបី ក្រសួង-ស្ថាប័ន និងអាជ្ញាធរមូលដ្ឋានពាក់ព័ន្ធនៃប្រទេសទាំងបីនឹងសម្របសម្រួលគ្នា ដើម្បីពិនិត្យឡើងវិញជាទៀងទាត់នូវកិច្ចព្រមព្រៀងដែលបានចុះហត្ថលេខាកន្លងមក, ពន្លឿនការអនុវត្ត និងផ្តល់ការណែនាំជាក់លាក់បន្ថែមទៀត សម្រាប់កិច្ចព្រមព្រៀងសហប្រតិបត្តិការពាណិជ្ជកម្មទ្វេភាគីដែលមានស្រាប់របស់ប្រទេសទាំងបី, ក្នុងរយៈពេលវែង គួរធ្វើការសិក្សា ដើម្បីផ្លាស់ប្តូរពីកិច្ចព្រមព្រៀងស្តីពីការជំរុញ និងសម្រួលពាណិជ្ជកម្ម ក្នុងតំបន់អភិវឌ្ឍន៍ត្រីកោណកម្ពុជា-ឡាវ-វៀតណាម ទៅជាកិច្ចព្រមព្រៀងស្តីពីការជំរុញ និងសម្រួលពាណិជ្ជកម្មរវាងប្រទេសទាំងបី។

២. អនុវត្តឲ្យមានប្រសិទ្ធភាពនូវកិច្ចព្រមព្រៀងដែលមានស្រាប់ ស្តីពីកម្មវិធីកាត់បន្ថយពន្ធគយលើមុខទំនិញ ដែលមានប្រភពដើមពីប្រទេសនីមួយៗ ព្រមទាំងគិតគូរឲ្យបានទាន់ពេលវេលា និងដោះស្រាយបញ្ហា និងឧបសគ្គនានាដែលពាក់ព័ន្ធនឹងការគ្រប់គ្រង និងចរាចរណ៍ទំនិញ ដើម្បីជំរុញផលិតកម្ម និងពាណិជ្ជកម្ម ក្នុងបណ្តាប្រទេសទាំងបី។

៣. សម្របសម្រួលការអនុវត្តគម្រោងសាងសង់ និងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធពាណិជ្ជកម្ម របស់បណ្តាប្រទេសទាំងបី ដើម្បីគាំទ្រដោយផ្ទាល់ និងប្រយោល ដល់សកម្មភាពសេដ្ឋកិច្ចសំខាន់ៗ និងបង្កើតយន្តការលើកទឹកចិត្តដើម្បីទាក់ទាញការវិនិយោគលើគម្រោងសាងសង់ផ្លូវថ្នល់ និងហេដ្ឋារចនាសម្ព័ន្ធពាណិជ្ជកម្មផ្សេងទៀត នៅតាមតំបន់សេដ្ឋកិច្ចតាមព្រំដែន។

៤. សហការឲ្យបានជិតស្និទ្ធរវាងភ្នាក់ងារពាក់ព័ន្ធនៃបណ្តាប្រទេសទាំងបី ក្នុងការអនុវត្តនីតិវិធីពន្ធគយ និងអន្តោ-ប្រវេសន៍ ដើម្បីជួយសម្របសម្រួលដល់ការធ្វើធុរកិច្ច និងប្រជាជន ឲ្យសន្សំសំចៃបានទាំងពេលវេលា និងចំណាយលើថ្លៃដឹកជញ្ជូន និងបង្កើតនូវលក្ខខណ្ឌអំណោយផលសម្រាប់ជនអន្តោប្រវេសន៍ ក្នុងការដាក់ពាក្យស្នើសុំទិដ្ឋាការនៅតាមច្រកព្រំដែនអន្តរជាតិ ឬការិយាល័យត្រួតពិនិត្យព្រំដែនអន្តរជាតិ។

៥. ស្ថាប័នគ្រប់គ្រងព្រំដែននៃប្រទេសទាំងបី ដូចជាគយ កាំកុងត្រូល នគរបាលអន្តោប្រវេសន៍ និងអាជ្ញាធរពាក់ព័ន្ធដទៃទៀត គួរធ្វើកិច្ចសហប្រតិបត្តិការឲ្យបានជិតស្និទ្ធ ក្នុងការផ្លាស់ប្តូរព័ត៌មានតាមច្រកព្រំដែនឲ្យគ្នាទៅវិញទៅមក ដើម្បីការពារ និងរឹតបន្តឹងការគេចពន្ធ និងបទល្មើសពាណិជ្ជកម្មនានា។

៦. រៀបចំពិព័រណ៍ពាណិជ្ជកម្មអន្តរជាតិ CLV ប្រចាំឆ្នាំប្តូរវេនគ្នា នៅក្នុងបណ្តាប្រទេសសមាជិក CLV ដោយមានការចូលរួមពីសំណាក់វិនិយោគិន និងធុរជនមកពីប្រទេសទាំងបី និងពីបណ្តាប្រទេសផ្សេងៗទៀតនៅក្នុងតំបន់ ដើម្បីជួយដល់វិនិយោគិន និងធុរជន ក្នុងការផ្សព្វផ្សាយ និងណែនាំផលិតផលរបស់ខ្លួន ព្រមទាំងការចាប់ដៃគូពាណិជ្ជកម្ម។

## ២.៦. ឧស្សាហកម្មសំខាន់ៗ

*១. លើកស្ទួយការតភ្ជាប់ខ្សែសង្វាក់ផ្គត់ផ្គង់កម្មន្តសាល ព្រមទាំងតំបន់សេដ្ឋកិច្ច និងសួនឧស្សាហកម្មក្នុងប្រទេសកម្ពុជា ឡាវ និងវៀតណាម*

- ពង្រឹងកិច្ចសហប្រតិបត្តិការ និងការតភ្ជាប់ផលិតកម្មឧស្សាហកម្មក្នុងប្រទេសកម្ពុជា ឡាវ និងវៀតណាម ក្នុងវិស័យឧស្សាហកម្មផលិតទំនិញប្រើប្រាស់សម្រាប់ការនាំចេញ ពង្រឹងការកែច្នៃកសិផល ផលិតកម្មឥន្ធនៈ វត្ថុធាតុដើម និងវត្ថុធាតុចាំបាច់សម្រាប់គោលនយោបាយជំនួសការនាំចូល ការរុករករ៉ែ និងការកែច្នៃស៊ីជម្រៅ ឧស្សាហកម្មគាំទ្រផ្សេងៗ និង ផលិតកម្មថាមពលអាចកើតឡើងវិញ។

- ផ្តល់អាទិភាពចំពោះការអភិវឌ្ឍ និងអនុវត្តកម្មវិធីសម្រាប់កិច្ចសហប្រតិបត្តិការ និងការតភ្ជាប់ខ្សែសង្វាក់ផ្គត់ផ្គង់ និងផលិតកម្មឧស្សាហកម្ម រហូតដល់ឆ្នាំ២០៣០ លើវិស័យនានា ដូចតទៅៈ

+ វិស័យបច្ចេកវិទ្យាព័ត៌មាន និងទូរគមនាគមន៍ (ICT) រួមមានគ្រឿងបង្គុំ (Hardware) គ្រឿងអេឡិចត្រូនិក កម្មវិធី (Software) និងមាតិកាឌីជីថល (Digital Content)
+ ឧស្សាហកម្មផលិតកម្មឧបករណ៍អេឡិចត្រូនិក និងទូរគមនាគមន៍
+ ពាណិជ្ជកម្មអេឡិចត្រូនិក
+ ឧស្សាហកម្មដែកថែប
+ ឧស្សាហកម្មកែច្នៃកៅស៊ូធម្មជាតិ
+ ឧស្សាហកម្មកែច្នៃកសិផល និងម្ហូបអាហារ
+ ឧស្សាហកម្មកែច្នៃផលិតផលឥន្ធនៈ និងសារធាតុគីមីសំយោគមកពីប្រេងឬឧស្ម័នធម្មជាតិ (petrochemical)
+ ឧស្សាហកម្មផលិតសារធាតុគីមី និងជី
+ កម្មន្តសាល និងផលិតកម្មសូត្រ ឧស្សាហកម្មវាយនភណ្ឌ និងសម្លៀកបំពាក់
+ ឧស្សាហកម្មផលិតស៊ីម៉ង់ និងសម្ភារៈសំណង់

+ ឧស្សាហកម្មគាំទ្រដល់ការផលិត និងតម្លើងយានយន្ត យានជំនិះ និងគ្រឿងម៉ាស៊ីនកសិកម្ម

+ ឧស្សាហកម្មផលិតថាមពលកកើតឡើងវិញ ប្រកបដោយចីរភាព

- ក្រសួង-ស្ថាប័នពាក់ព័ន្ធ ព្រមទាំងក្រុមប្រឹក្សាភិបាលគ្រប់គ្រងតំបន់សេដ្ឋកិច្ច (EZ) និងសួនឧស្សាហកម្ម (IP) ក្នុងប្រទេសទាំងបី សម្របសម្រួលជាមួយគ្នា ដើម្បីអភិវឌ្ឍន៍បណ្តាញផ្លាស់ប្តូរព័ត៌មាន និងធ្វើឲ្យកាន់តែជាក់លាក់នូវការតភ្ជាប់ ការផ្លាស់ប្តូរ និងសហប្រតិបត្តិការលើការទាក់ទាញវិនិយោគ ការបណ្តុះបណ្តាលកម្លាំងពលកម្ម និងការផ្គត់ផ្គង់កម្មករជំនាញ និងអ្នកជំនាញវិជ្ជាជីវៈ (professionals) សម្រាប់ការធ្វើធុរកិច្ច/វិនិយោគ ក្នុងតំបន់សេដ្ឋកិច្ច និងសួនឧស្សាហកម្ម។

- បង្កើតយន្តការ និងគោលនយោបាយអនុគ្រោះសម្រាប់ធុរកិច្ច CLV ដោយធ្វើការសហការ ធ្វើការវិនិយោគ និងបង្កើតក្រុមហ៊ុនវិនិយោគរួមគ្នា រវាងប្រទេសសមាជិក CLV និង CLV+ ដែលវិនិយោគក្នុងការអភិវឌ្ឍ និងប្រតិបត្តិការតំបន់សេដ្ឋកិច្ច (EZ) និងសួនឧស្សាហកម្ម(IP)នានា ក្នុងបណ្តាប្រទេសទាំងបី។

- ផ្សាភ្ជាប់ផែនការមេសម្រាប់ប្រព័ន្ធតំបន់សេដ្ឋកិច្ច (EZ) និងសួនឧស្សាហកម្ម(IP) ក្នុងប្រទេសនីមួយៗ ព្រមទាំងធ្វើកិច្ចសហប្រតិបត្តិការក្នុងការទាក់ទាញការវិនិយោគ ដើម្បីបង្កើត និងអភិវឌ្ឍតំបន់ឧស្សាហកម្មរួម CLV តាមទីតាំងភូមិសាស្ត្រ ដែលអាចជួយសម្រួលដល់ការអភិវឌ្ឍទៅវិញទៅមក និងការទាញយកផលប្រយោជន៍ប្រកបដោយប្រសិទ្ធផល ពីច្រករបៀងសេដ្ឋកិច្ចមហាអនុតំបន់ទន្លេមេគង្គ ផ្លូវអន្តរអាស៊ី (Trans-Asia) និងផ្លូវជាតិឆ្លងកាត់ព្រំដែន ។

*២. លើកស្ទួយការតភ្ជាប់ធុរកិច្ច ដើម្បីចូលរួមក្នុងខ្សែសង្វាក់ផ្គត់ផ្គង់ និងផលិតកម្ម កម្ពុជា ឡាវ និងវៀតណាម*

- លើកទឹកចិត្ត/ចាត់តាំងឲ្យសភាពាណិជ្ជកម្ម និងឧស្សាហកម្ម សមាគមធុរកិច្ច សមាគមអ្នកជំនាញវិជ្ជាជីវៈ អាជ្ញាធរមូលដ្ឋាន និងស្ថាប័នពាក់ព័ន្ធនៃប្រទេសទាំងបី ធ្វើការសម្របសម្រួលគ្នាទៅវិញទៅមក ក្នុងការតភ្ជាប់ទំនាក់ទំនងធុរកិច្ច និងវិនិយោគិន សម្រាប់ចូលរួមអភិវឌ្ឍខ្សែសង្វាក់ផ្គត់ផ្គង់ និងផលិតកម្ម កម្ពុជា ឡាវ និងវៀតណាម។

- ការសម្របសម្រួលគួរធ្វើឡើង ដើម្បីអភិវឌ្ឍ និងអនុវត្តការជំរុញវិនិយោគ និងផែនការនិងកម្មវិធី សហ-ប្រតិបត្តិការ ដោយធុរជន និងវិនិយោគិនរបស់ប្រទេសទាំងបី និងដៃគូ សម្រាប់ចូលរួមការអភិវឌ្ឍខ្សែសង្វាក់ផ្គត់ផ្គង់ និងផលិតកម្មរបស់ប្រទេស CLV និង CLV+ ថ្នាក់តំបន់ ថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន។

- បង្កើតលក្ខខណ្ឌអនុគ្រោះសម្រាប់សហគ្រាសក្នុងប្រទេសកម្ពុជា ឡាវ និងវៀតណាម ដើម្បីបង្កើតសហគ្រាសវិនិយោគរួម និងចូលរួមទុនក្រោមទម្រង់ផ្សេងៗ ដូចជា ធនធានហិរញ្ញវត្ថុ បណ្តាញបច្ចេកវិទ្យា និងការទិញភាគហ៊ុន។

- បង្កើតលក្ខខណ្ឌអនុគ្រោះសម្រាប់ក្រុមហ៊ុនទិញសិទ្ធិលក់ដូរ (Franchise) និងក្រុមហ៊ុនបញ្ចូលគ្នា និងការទិញយក (merger and acquisition) ក្នុងចំណោមសហគ្រាសនៃប្រទេសកម្ពុជា ឡាវ និងវៀតណាម ស្របតាមច្បាប់ និងបទប្បញ្ញត្តិរបស់ប្រទេសនីមួយៗ។ លើកទឹកចិត្តដល់ធុរជន និងវិនិយោគិននៃប្រទេសកម្ពុជា ឡាវ និងវៀតណាម ដែលមានគម្រោងវិនិយោគដោយផ្ទាល់ពីបរទេស (FDI) នៅក្នុងប្រទេសទាំងបី ក្នុងការអនុវត្តការបណ្តាក់ទុនបន្ថែម និងចុះឈ្មោះក្នុងទីផ្សារដោះដូរមូលបត្រនៅក្នុងប្រទេសជាម្ចាស់ផ្ទះ។

*៣. ជំរុញការតភ្ជាប់ខ្សែសង្វាក់ផ្គត់ផ្គង់ និងផលិតកម្មក្នុងវិស័យកសិកម្មរបស់ប្រទេសកម្ពុជា ឡាវ និងវៀតណាម*

- ពង្រឹងកិច្ចសហប្រតិបត្តិការ និងការតភ្ជាប់ក្នុងប្រទេសកម្ពុជា ឡាវ និងវៀតណាម ក្នុងដំណើរការផលិតកម្មផលិតផលកសិកម្មធម្មជាតិនិងមានសុវត្ថិភាព និងម្ហូបអាហារ ផលិតផលកសិកម្មដែលមិនប៉ះពាល់ខ្លាំងដល់បរិស្ថាន និងកសិកម្មអេកូឡូជី ដែលអាចសម្របនឹងការប្រែប្រួលអាកាសធាតុ។

- ជំរុញការអនុវត្តស្តង់ដារ/ការអនុវត្តពាក់ព័ន្ធនឹងវិស័យកសិកម្ម ព្រមទាំងអនាម័យ និងភូតគាមអនាម័យ (SPS)។ អនុវត្តការបែងចែកតំបន់គ្រប់គ្រងជំងឺសត្វ និងជំងឺមាត់ និងជើង (FMD Control Progressive Zoning)។

- ជំរុញផលិតកម្ម/ការចិញ្ចឹមគោយកទឹកដោះ និងសាច់ និងការបង្កាត់ពូជ ព្រមទាំងការកែច្នៃផលិតផលធ្វើពីទឹកដោះ។

- ពង្រឹងការដាំដុះ និងការកែច្នៃម្ហូបអាហារផ្អែកកសិផល ដូចជាស្រូវដែលមានគុណភាពខ្ពស់ ពោតដែលទទួលទិន្នផលខ្ពស់ បន្លែផ្លែឈើដែលមានសុវត្ថិភាព និងចំណីសត្វ ស្របតាមការអនុវត្តកសិកម្មល្អ (Good Agricultural Practice-GAP) ព្រមទាំងការដាំដុះ និងកែច្នៃដំណាំសម្រាប់លក់/សម្រាប់ឧស្សាហកម្ម ដូចជាកប្បាស គ្រាប់ស្វាយចន្ទី កាហ្វេ ស្ករស និងកៅស៊ូ (ចំពោះប្រទេសឡាវ គឺមានតែការកែច្នៃកៅស៊ូតែប៉ុណ្ណោះ)។

- ជំរុញសកម្មភាព និងការកែច្នៃវារីវប្បកម្ម។

- លើកកម្ពស់ផលិតភាពពីព្រៃឈើ (ការដាំដុះក្នុងព្រៃ និងការដាំព្រៃឈើឡើងវិញ)។

-ធ្វើការស្រាវជ្រាវ អភិវឌ្ឍ កែលម្អឲ្យបានសកម្ម និងឈានទៅរកការអនុវត្តប្រកបដោយប្រសិទ្ធភាពនូវផែនការដែលបានអនុម័តរួចហើយ ស្តីពីការអភិវឌ្ឍឧស្សាហកម្មកៅស៊ូក្នុងតំបន់អភិវឌ្ឍន៍ត្រីកោណកម្ពុជា-ឡាវ-វៀតណាម (CLV-DTA)។

- លើកទឹកចិត្ត និងគាំទ្រដល់សហគ្រាសវិនិយោគរួមនៃប្រទេសកម្ពុជា ឡាវ និងវៀតណាម ដែលវិនិយោគលើបច្ចេកវិទ្យាកម្រិតខ្ពស់ និងទំនើបក្នុងវិស័យកសិកម្ម ព្រមទាំងលើកទឹកចិត្ត និងគាំទ្រគម្រោងពាក់ព័ន្ធនឹងកម្មវិធីដែលមានបច្ចេកវិទ្យាខ្ពស់ (High-tech Applications) ដែលប្រើប្រាស់សម្រាប់ផលិតកម្មក្នុងការដាំដុះ និងគ្រាប់ពូជដែលមានគុណភាពនិងទិន្នផលខ្ពស់ ដើម្បីផ្គត់ផ្គង់ទីផ្សារក្នុងស្រុកនៃប្រទេសទាំងបី។

## ២.៧. វិស័យហិរញ្ញវត្ថុ និងធនាគារ

១. ប្រទេសកម្ពុជា ឡាវ និងវៀតណាម គួរសិក្សា និងចេញផ្សាយនូវឯកសារផ្លូវច្បាប់ជាបន្ទាន់ ដើម្បីកែលម្អបរិយាកាសធុរកិច្ច ពាក់ព័ន្ធនឹងដំណើរការរបស់ធនាគារ និងស្ថាប័នហិរញ្ញវត្ថុនៅក្នុងសាមីប្រទេសស្របតាមកិច្ចព្រមព្រៀងពហុភាគី និងទ្វេភាគី និងផែនការមេ ដែលបានសន្យា។

២. ប្រទេសកម្ពុជា ឡាវ និងវៀតណាម គួរកាត់បន្ថយគម្លាតអភិវឌ្ឍន៍ក្នុងវិស័យហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាធនាគារ នៅក្នុងប្រទេសកម្ពុជា ឡាវ និងវៀតណាម និងបណ្តាប្រទេសដទៃទៀតក្នុងតំបន់។ គួរជំរុញការរៀបចំប្រព័ន្ធទូទាត់សាច់ប្រាក់តាមធនាគារបែបទំនើប ប្រកបដោយសុវត្ថិភាព និងប្រសិទ្ធផល ឲ្យអនុលោមតាមបទដ្ឋានអន្តរជាតិ។

៣. ផ្លាស់ប្តូរកិច្ចសហប្រតិបត្តិការបច្ចេកទេស រវាងធនាគារកណ្តាលនៃប្រទេសកម្ពុជា ឡាវ និងវៀតណាម ឲ្យបានទៀងទាត់។ ទន្ទឹមនឹងនោះដែរ ប្រទេសទាំងបីត្រូវលើកកម្ពស់កិច្ចសហប្រតិបត្តិការដើម្បីកែលម្អមូលដ្ឋានច្បាប់សម្រាប់ប្រឆាំងនឹងការលាងលុយកខ្វក់ និងប្រឆាំងទៅនឹងការផ្តល់ហិរញ្ញវត្ថុដល់ភេរវកម្ម អនុលោមតាមការសន្យារវាងប្រទេសទាំងបី ដែលជាហត្ថលេខីក្នុងក្រុមការងារប្រតិបត្តិការហិរញ្ញវត្ថុ (Financial Action Task Force-FATF) និងក្រុមលាងលុយកខ្វក់អាស៊ីប៉ាស៊ីហ្វិក (Asia-Pacific Group on Money Laundering-APG)។

## ២.៨. ធនធានធម្មជាតិ បរិស្ថាន និងការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ

១. សហប្រតិបត្តិការឲ្យបានជិតស្និទ្ធក្នុងការខិតខំប្រឹងប្រែងរួមគ្នា ដើម្បីការពារបរិស្ថាន និងការអភិរក្សធនធានធម្មជាតិ។ ប្រទេសទាំងបី គួរជំរុញការចែករំលែកបទពិសោធន៍ និងសម្របសម្រួលការអភិវឌ្ឍកម្មវិធី និងគម្រោងកិច្ចសហប្រតិបត្តិការជាក់លាក់សម្រាប់វិស័យឧតុនិយម ការប្រើប្រាស់ និងផលិតកម្មប្រកបដោយចីរភាព ការជូនដំណឹងអំពីគ្រោះធម្មជាតិ និងការឆ្លើយតបទៅនឹងហេតុការណ៍ ក្នុងកំឡុង និងក្រោយពេលគ្រោះធម្មជាតិកើតឡើងដែលមានផលប៉ះពាល់ជាអន្តរកាល។ ជាមួយគ្នានេះដែរ ប្រទេសទាំងបីប្តេជ្ញាយ៉ាងមោះមុត និងបន្តការប្រឹងប្រែងយ៉ាងខ្លាំង ឆ្ពោះទៅរកការកាត់បន្ថយផលប៉ះពាល់ដល់ការប្រែប្រួលអាកាសធាតុ និងកាត់បន្ថយកាបូន សម្របសម្រួលការអនុវត្ត និងធ្វើឲ្យជាក់លាក់នូវយុទ្ធសាស្ត្រអភិវឌ្ឍន៍បៃតង ដែលត្រូវបាន ឬកំពុងរៀបចំកន្លងមកនៅក្នុង

ប្រទេសទាំងបី ព្រមទាំងការពារ និងរឹតបណ្ដឹងការធ្វើពាណិជ្ជកម្មឈើ ផលិតផលពីព្រៃឈើ និងជលផល ឆ្លងដែនខុសច្បាប់។

២. អនុវត្តនូវកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធរវាងប្រទេសកម្ពុជា ឡាវ និងវៀតណាម ដើម្បីការពារប្រព័ន្ធអេកូឡូជីឆ្លងព្រំដែន ដែលស្ថិតនៅតំបន់ព្រំដែននៃប្រទេសទាំងបី ពិសេសនៅតំបន់អភិវឌ្ឍន៍ត្រីកោណកម្ពុជា-ឡាវ-វៀតណាម និងអាងទន្លេមេគង្គ។ លើសពីនេះទៅទៀត កិច្ចខិតខំប្រឹងប្រែងដែលកំពុងបន្ត និងយុទ្ធសាស្ត្របន្ស៊ាំបន្សារអាកាសធាតុ ព្រមទាំងផែនការសកម្មភាពជាក់លាក់ របស់គណៈកម្មាធិការទន្លេមេគង្គ ដែលបានជ្រើសរើសរួចហើយ ដោយប្រទេសទាំងបី គួរត្រូវបញ្ចូលទៅក្នុងផែនការសកម្មភាពនេះ។

៣. លើកស្ទួយការចែករំលែកបទពិសោធន៍ និងកិច្ចសហប្រតិបត្តិការការពារព្រៃឈើនៅតាមព្រំដែនរួម សត្វព្រៃ ព្រមទាំងការការពារជីវៈចម្រុះ និងការអនុវត្តគម្រោងរួម ដែលមានគោលបំណងធ្វើឲ្យប្រសើរឡើងនូវការអប់រំស្ដីពីបរិស្ថាន និងការគ្រប់គ្រងទីជំរាល ក៏ដូចជាការកាត់បន្ថយភាពសឹករេចរឹល និងបាត់បង់ព្រៃឈើ ឲ្យស្របទៅនឹងយន្តការ REDD+ (កាត់បន្ថយការបញ្ចេញផ្សែងពុលដោយសារការកាប់បំផ្លាញ និងភាពសឹករេចរឹលនៃព្រៃឈើ)។ ទន្ទឹមនឹងនេះ ភាគីទាំងអស់ត្រូវសម្របសម្រួលជាមួយគ្នាឲ្យបានជិតស្និទ្ធ ដើម្បីអភិរក្សព្រៃឈើនៅតំបន់អភិវឌ្ឍន៍ត្រីកោណនៃប្រទេសទាំងបី បង្កើត និង/ឬពង្រឹងយន្តការសម្របសម្រួលអន្តរស្ថាប័ន ដើម្បីការពារការទន្ទ្រានព្រៃឈើ និងការដឹកជញ្ជូនខុសច្បាប់។

៤. សហការក្នុងការទាក់ទាញគម្រោងវិនិយោគ និងជំនួយបរទេសក្នុងវិស័យការពារបរិស្ថាន និងអភិរក្ស ធនធានធម្មជាតិ ដោយជំនះនូវបញ្ហាហិរញ្ញវត្ថុ ធនធានមនុស្ស ហេដ្ឋារចនាសម្ព័ន្ធ និងបច្ចេកវិទ្យាសម្រាប់ការការពារបរិស្ថាន។

៥. យកចិត្តទុកដាក់លើគំនិតផ្ដួចផ្ដើមរបស់ប្រទេសកម្ពុជា ឡាវ និងវៀតណាម ដើម្បីទទួលបានហិរញ្ញវត្ថុពីកិច្ចប្រជុំសន្និបាតបរិស្ថានសកល (Global Environment Facility-GEF) ដែលនឹងរៀបចំនៅប្រទេសវៀតណាម និងកិច្ចប្រជុំដទៃទៀត។

៦. ធ្វើឲ្យប្រសើរឡើងនូវយន្តការដែលមានស្រាប់ សម្រាប់កិច្ចសហប្រតិបត្តិការ និងការចែករំលែកព័ត៌មានស្ដីអំពីការប្រែប្រួលអាកាសធាតុ និងការអភិរក្សធនធានទឹក និងធនធានពាក់ព័ន្ធ តាមទន្លេមេគង្គ ដើម្បីជានាផលប្រយោជន៍រួមនៃប្រទេសកម្ពុជា ឡាវ និងវៀតណាម។

### ២.៩. វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា

ពន្លឿនការអនុវត្តគម្រោងសហប្រតិបត្តិការរវាងប្រទេសទាំងបីលើវិស័យវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ស្តង់ដារ មាត្រដ្ឋាន និងកម្មសិទ្ធិបញ្ញា ជាពិសេសគម្រោងជំនួយបច្ចេកទេស ការផ្លាស់ប្តូរព័ត៌មាន និងការកសាងសមត្ថភាព ក្នុងវិស័យវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា និងការផ្ទេរបច្ចេកវិទ្យា។

### ២.១០. ការសម្អាតមីន និងអាវុធយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ (UXO)

ពង្រឹងកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងបី ក្នុងវិស័យសម្អាតមីន និងអាវុធយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ (UXO) ដើម្បីធ្វើឲ្យផ្ទៃដីមានសុវត្ថិភាព និងអាចប្រើប្រាស់បានសម្រាប់ប្រជាជន ការធ្វើកសិកម្ម កសិ-ឧស្សាហកម្ម និងគម្រោងអភិវឌ្ឍន៍វិនិយោគ។

## III. ការតភ្ជាប់ទំនាក់ទំនងរវាងប្រជាជននិងប្រជាជន និងកិច្ចសហប្រតិបត្តិការតាមតំបន់ព្រំដែន

### ៣.១. ការអប់រំ និងបណ្តុះបណ្តាល

១. ប្រទេសកម្ពុជា ឡាវ និងវៀតណាម លើកទឹកចិត្តវិនិយោគិនមកពីវិស័យសេដ្ឋកិច្ចផ្សេងៗ ឲ្យធ្វើការវិនិយោគលើការអប់រំ និងបណ្តុះបណ្តាល ស្របតាមបទប្បញ្ញត្តិទូទៅនៃសហគមន៍សេដ្ឋកិច្ចអាស៊ាន ព្រមទាំងច្បាប់ និងបទប្បញ្ញត្តិនានារបស់ប្រទេសនីមួយៗ។

២. ផ្លាស់ប្តូរឲ្យបានទៀងទាត់នូវ ព័ត៌មានស្តីពីទីផ្សារការងារ និងការព្យាករអំពីតម្រូវការ និងការផ្គត់ផ្គង់ការងារ ក្នុងចំណោមប្រទេសកម្ពុជា ឡាវ និងវៀតណាម និងកែលម្អសមត្ថភាពស្ថាប័នបណ្តុះបណ្តាល ដើម្បីឆ្លើយតបទៅនឹងតម្រូវការទីផ្សារការងារ ជាពិសេសនៅក្នុងប្រទេសទាំងបី និងជាទូទៅនៅក្នុងទីផ្សារអាស៊ានទាំងមូល ដោយពិចារណាលើឥទ្ធិពលនៃបដិវត្តន៍ឧស្សាហកម្មទី៤ ដែលមានលក្ខណៈកាន់តែស៊ីជម្រៅ និងទូលំទូលាយ។

៣. ពង្រឹងកិច្ចសហប្រតិបត្តិការក្នុងវិស័យបណ្តុះបណ្តាលវិជ្ជាជីវៈ និងការអប់រំថ្នាក់ឧត្តម ដោយផ្តោតលើជំនាញវិជ្ជាជីវៈចំនួន៨ ដែលបានព្រមព្រៀងគ្នារួចហើយ ដើម្បីឲ្យពលករជំនាញអាចធ្វើដំណើរដោយសេរីក្នុងតំបន់អាស៊ាន រួមមាន៖ វិស្វករ គិលានុបដ្ឋាយិកា ស្ថាបត្យករ អ្នកស្រាវជ្រាវ គ្រូពេទ្យឯកទេស(Physician) ទន្តបណ្ឌិត គណនេយ្យករ និងអ្នកវិជ្ជាជីវៈទេសចរណ៍។ ប្រទេសកម្ពុជា ឡាវ និងវៀតណាម ត្រូវពិចារណាលើជំនាញវិជ្ជាជីវៈបន្ថែម ដើម្បីផ្តល់ផលប្រយោជន៍ដល់ការអភិវឌ្ឍនៃប្រទេសទាំងបី។ ទន្ទឹមនឹងនេះ ធ្វើការសិក្សាអំពីការបង្កើតកម្មវិធីរួម ស្តីពីសហប្រតិបត្តិការបណ្តុះបណ្តាលភាសាខ្មែរ ឡាវ និងវៀតណាម ដល់ពលករមកពីប្រទេសទាំងបី។

៤. ពង្រីកកិច្ចសហប្រតិបត្តិការ និងផ្លាស់ប្តូរព័ត៌មាននិងប្រតិបត្តិការជំនាញ ផ្តល់នូវការបណ្តុះបណ្តាល និងលើកកម្ពស់គុណភាពគ្រូបង្រៀន និងសាស្ត្រាចារ្យ នៃប្រទេសទាំងបី ជាពិសេសនៅក្នុងវិស័យដែលប្រទេសនីមួយៗមានជំនាញ ដូចជាការអប់រំទូទៅ និងឧត្តមសិក្សា ការបណ្តុះបណ្តាលវិជ្ជាជីវៈ ហិរញ្ញវត្ថុ ធនាគារ បច្ចេកវិទ្យា ព័ត៌មានវិទ្យា និងទូរគមនាគមន៍ (ICT)។

៥. ពង្រីក និងធ្វើពិពិធកម្មលើទម្រង់នៃការបណ្តុះបណ្តាល/ការអប់រំថ្នាក់ឧត្តមសិក្សា (រយៈពេលវែង រយៈពេលខ្លី ការបណ្តុះបណ្តាលមូលដ្ឋាន ការបណ្តុះបណ្តាលឡើងវិញ វគ្គបណ្តុះបណ្តាលកម្រិតខ្ពស់ ការអប់រំវិជ្ជាជីវៈ និងការស្រាវជ្រាវរួម) ដោយផ្តោតលើវិស័យមួយចំនួន ដូចជា ទេសចរណ៍ សុខាភិបាល បច្ចេកវិទ្យាព័ត៌មានវិទ្យានិងទូរគមនាគមន៍ (ICT) និងប្រៃសណីយ៍និងទូរគមនាគមន៍ ធនាគារ សេវាធានារ៉ាប់រង មូលបត្រ និងវិស័យផ្សេងទៀត ទទួលស្គាល់គ្នាទៅវិញទៅមកលើគុណភាព និងលើកទឹកចិត្តដល់ស្ថាប័នអប់រំនិងបណ្តុះបណ្តាល នៅក្នុងប្រទេសទាំងបីឲ្យសហការរៀបចំការបណ្តុះបណ្តាលរួមគ្នា។

## ៣.២. វិស័យសុខាភិបាល

១. លើកទឹកចិត្ត និងជំរុញការវិនិយោគក្នុងវិស័យថែទាំសុខភាព រួមមានជំងឺឆ្លង និងជំងឺរីករាលដាលនានា ដើម្បីឲ្យស្របតាមច្បាប់ និងបទប្បញ្ញត្តិ ដែលប្រទេសនីមួយៗ។ ប្រសិនបើចាំបាច់ ភាគីទាំងបីត្រូវធ្វើការពិនិត្យឡើងវិញនូវចន្លោះខ្វះខាតណាមួយ ដែលអាចធ្វើវិសោធនកម្ម និង/ឬបំពេញបន្ថែមលើចំណុចខ្វះចន្លោះទាំងនោះ ដើម្បីសម្រួលដល់ការវិនិយោគទាំងនេះ។

២. ពង្រឹងកិច្ចសហប្រតិបត្តិការលើបញ្ហាសុវត្ថិភាពចំណីអាហារ សុខភាពកុមារនិងមាតា ការអប់រំ និងទំនាក់ទំនងស្តីពីសុខាមាលភាព។

៣. ពង្រឹងសមត្ថភាពធនធានមនុស្សក្នុងវិស័យសុខាភិបាល ដើម្បីប្រយុទ្ធប្រឆាំងនឹងជំងឺឆ្លង និងជំងឺរីករាលដាលនៅក្នុងប្រទេសទាំងបី ជាពិសេសនៅតាមតំបន់ព្រំដែននៃប្រទេសទាំងបី តាមរយៈការបណ្តុះបណ្តាល និង/ឬការផ្លាស់ប្តូរចំណេះដឹង និងបទពិសោធន៍ក្នុងការគ្រប់គ្រង និងទប់ស្កាត់ជំងឺ ជាពិសេសក្នុងកាលៈទេសៈដែលមានការផ្ទុះចេញនូវជំងឺឆ្លង។

៤. ជំរុញកិច្ចសហប្រតិបត្តិការរវាងអាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសទាំងបី ក្នុងការប្រយុទ្ធប្រឆាំងនឹងការផលិត និងការធ្វើពាណិជ្ជកម្មផលិតផលគ្រឿងសម្អាង និងសារធាតុគីមី ផលិតផលឱសថ និងឧបករណ៍វេជ្ជសាស្ត្រក្លែងក្លាយ និងក្រោមស្តង់ដារ តាមរយៈការផ្លាស់ប្តូរព័ត៌មាន បទពិសោធន៍ និងចំណេះដឹងពីប្រទេសទាំងបី និងកិច្ចសហប្រតិបត្តិការលើការស្រាវជ្រាវ ការកែច្នៃ និងការផលិតឱសថ នៅក្នុងប្រទេសទាំងបី។

៥. ពង្រឹងយន្តការសម្របសម្រួលដែលមានស្រាប់ ដើម្បីគ្រប់គ្រង និងការពារជំងឺ នៅតាមតំបន់ព្រំដែន ដោយរាប់បញ្ចូលការផ្លាស់ប្តូរព័ត៌មាន រវាងអាជ្ញាធរមូលដ្ឋានដែលពាក់ព័ន្ធនៃប្រទេសទាំងបី។

៦. សម្របសម្រួលការកៀងគរមូលនិធិ និងវិនិយោគលើវិស័យសុខាភិបាល ដើម្បីកែលម្អមន្ទីរពេទ្យស្ថិតក្នុងប្រទេសទាំងបីឲ្យបានកាន់តែល្អ ជាពិសេសនៅតាមតំបន់ព្រំដែននៃប្រទេសទាំងបី។

៧. ជំរុញការផ្លាស់ប្តូរ អ្នកមានជំនាញវិជ្ជាជីវៈក្នុងវិស័យសុខាភិបាល។

## ៣.៣. កិច្ចសហប្រតិបត្តិការក្នុងការប្រើប្រាស់កម្លាំងពលកម្ម

១. បន្តការធ្វើសាមញ្ញភាពទៅលើនីតិវិធី ដើម្បីសម្រួលដល់ការធ្វើដំណើរនៃពលករជំនាញ ជាពិសេសពលករដែលមានគុណវុឌ្ឍិខ្ពស់ សម្រាប់គម្រោងវិនិយោគនៃប្រទេសទាំងបី និង អភិវឌ្ឍនិងចែករំលែកព័ត៌មាន ស្ថិតិ និងការព្យាករលើនិន្នាការនៃតម្រូវការទីផ្សារការងារនៅក្នុងប្រទេសកម្ពុជា ឡាវ និងវៀតណាម ដើម្បីឲ្យប្រជាជន ធុរកិច្ច និងស្ថាប័នបណ្តុះបណ្តាលនៃប្រទេសនីមួយៗអាចកំណត់បាននូវទិសដៅបណ្តុះបណ្តាល ឲ្យបានសមស្របទៅតាមតម្រូវការទីផ្សារការងារ។

២. សម្របសម្រួលការគ្រប់គ្រងពលករបរទេសឲ្យបានតឹងរឹងនៅក្នុងប្រទេសនីមួយៗ ហើយស្របគ្នានេះធ្វើសាមញ្ញភាព ទៅលើនីតិវិធីសម្រាប់ការចុះបញ្ជីការងារ ការប្រមូលយកកម្រៃ និងថ្លៃសេវា តាមរយៈការចាប់ផ្តើមដំណើរការប្រព័ន្ធទូទាត់អេឡិចត្រូនិក ដែលទាក់ទងនឹងការងាររបស់ពលករបរទេស ស្របតាមច្បាប់ និងបទប្បញ្ញត្តិនៃប្រទេសនីមួយៗ។

៣. ជំរុញ និងអនុវត្តគោលនយោបាយអនុគ្រោះដល់ការធ្វើគម្រោងធុរៈកិច្ច និងវិនិយោគ ដោយប្រើប្រាស់ពលកម្មនៅក្នុងប្រទេសទាំងបី។

## ៣.៤. វប្បធម៌ កីឡា និងទេសចរណ៍

*១. បង្កើនកិច្ចសហប្រតិបត្តិការ និងការតភ្ជាប់ផ្នែកវប្បធម៌ និងកីឡា*

- ជំរុញការផ្លាស់ប្តូរសកម្មភាពវប្បធម៌ កីឡា និងទេសចរណ៍របស់អង្គភាពដែលពាក់ព័ន្ធ ក្នុងចំណោមប្រទេសទាំងបី ជាពិសេសខេត្តជាប់ព្រំដែន។ សេចក្តីលម្អិតនៃសកម្មភាពផ្លាស់ប្តូររបស់ប្រទេសទាំងបី ត្រូវសម្រេច និងយល់ព្រម ដោយអាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសទាំងបី។

- ពង្រីកវិសាលភាពនៃទូរទស្សន៍ និងវិទ្យុក្នុងប្រទេសទាំងបី ពិសេសនៅតាមតំបន់ព្រំដែន។

- ចែករំលែកបទពិសោធន៍ និងការគាំទ្រគ្នាទៅវិញទៅមក ក្នុងការកសាងសមត្ថភាពវិជ្ជាជីវៈដល់បុគ្គលិកក្នុងវិស័យវប្បធម៌ ព័ត៌មាន កាសែត វិទ្យុ និងទូរទស្សន៍ តាមរយៈការបណ្តុះបណ្តាល និងផ្លាស់ប្តូរបេសកកម្ម/ការធ្វើទស្សនកិច្ចប្រចាំឆ្នាំ។ បង្កើនការផ្លាស់ប្តូរ និងកិច្ចសហប្រតិបត្តិការរវាងស្ថាប័នសារព័ត៌មាន និងមជ្ឈមណ្ឌលព័ត៌មាននៃប្រទេសទាំងបី។

- គាំទ្រ និងជួយគ្នាទៅវិញទៅមកយ៉ាងសកម្ម ព្រមទាំងចែករំលែកបទពិសោធន៍ក្នុងការរៀបចំ និងធ្វើជាម្ចាស់ផ្ទះនៃព្រឹត្តិការណ៍វប្បធម៌ និងកីឡា ព្រមទាំងការបណ្តុះបណ្តាលកីឡានៅក្នុងប្រទេសទាំងបី។

- ពង្រឹងកិច្ចសហប្រតិបត្តិការក្នុងការការពារ និងអភិរក្សធនធានវប្បធម៌៖

- ប្រទេសទាំងបីត្រូវពិចារណាបង្កើតកិច្ចព្រមព្រៀងការពារការលួច ការជីកគាស់កាយ និងការនាំចេញ និងនាំចូលសម្បត្តិវប្បធម៌។
- ប្រទេសទាំងបីត្រូវសហការបង្កើតវិធានការកែលម្អ និងការពារជាចាំបាច់ ដើម្បីប្រយុទ្ធប្រឆាំងនឹងសកម្មភាពខុសច្បាប់ និងឧក្រិដ្ឋកម្មទាក់ទងនឹងការលួច ការជីកគាស់កាយ និងការនាំចេញនិងនាំចូលសម្បត្តិវប្បធម៌ ស្របតាមច្បាប់ក្នុងស្រុកនៃប្រទេសនីមួយៗ។
- ប្រទេសទាំងបីត្រូវបង្កើតកម្មវិធីប្រតិបត្តិការ ដើម្បីអភិរក្សវប្បធម៌ និងប្រពៃណីនៃក្រុមជនជាតិដើមនៅក្នុងតំបន់អភិវឌ្ឍន៍ត្រីកោណ CLV-DTA។

*២. ពង្រឹងកិច្ចសហប្រតិបត្តិការ និងការតភ្ជាប់វិស័យទេសចរណ៍*

- សម្របសម្រួលការពិនិត្យឡើងវិញ និងការជំរុញការអនុវត្តកិច្ចព្រមព្រៀងសហប្រតិបត្តិការអភិវឌ្ឍវិស័យទេសចរណ៍ និងការបញ្ចប់ឲ្យបានឆាប់នូវសេចក្តីព្រាងផែនការអភិវឌ្ឍន៍វិស័យទេសចរណ៍ក្នុងការអភិវឌ្ឍតំបន់ត្រីកោណ កម្ពុជា-ឡាវ-វៀតណាម(CLV-DTA)។

-ធ្វើការសិក្សារួម អំពីការលើកស្ទួយវិស័យទេសចរណ៍ និងបង្កើតលក្ខខណ្ឌអំណោយផលសម្រាប់អ្នកទេសចរ ដើម្បីឲ្យពួកគេធ្វើដំណើរកំសាន្តនៅក្នុងប្រទេសទាំងបីបានរលូន។

-អភិវឌ្ឍឲ្យបានសកម្មនូវហេដ្ឋារចនាសម្ព័ន្ធទេសចរណ៍ សហការបង្កើតផលិតផលទេសចរណ៍ និងតភ្ជាប់បណ្តាញនិងគោលដៅទេសចរណ៍នៅក្នុងប្រទេសទាំងបី។

-បន្តកិច្ចសហប្រតិបត្តិការលើការអភិវឌ្ឍធនធានមនុស្ស និងការបណ្តុះបណ្តាលលើវិស័យទេសចរណ៍ ក្រោមគម្រោងបណ្តុះបណ្តាល ៥ឆ្នាំ និងប្រចាំឆ្នាំ ព្រមទាំងបង្កើតស្តង់ដារឲ្យបានសមស្របតាមសំណើរបស់អាស៊ាន ដែលជាមូលដ្ឋានសម្រាប់ការផ្តល់វិញ្ញាបនបត្រលើសេវាទេសចរណ៍។

-ពង្រឹងការចែករំលែកបទពិសោធន៍លើការគ្រប់គ្រងគោលដៅទេសចរណ៍ និងការអភិវឌ្ឍទេសចរណ៍ប្រកបដោយនិរន្តរភាព សម្របសម្រួលការលើកកម្ពស់វិស័យទេសចរណ៍ ក្រោមក្របខណ្ឌអាស៊ាន អេកម៉ិក មហាអនុតំបន់មេគង្គ និងCLMV ចូលរួមក្នុងព្រឹត្តិការណ៍ទេសចរណ៍អន្តរជាតិសំខាន់ៗ ដែលរៀបចំដោយប្រទេសនីមួយៗ។

## ៣.៥. កិច្ចសហប្រតិបត្តិការតាមព្រំដែន និងការតភ្ជាប់រវាងប្រជាជននិងប្រជាជន

*១. ផ្តោតលើការដោះស្រាយបញ្ហា ខិតខំប្រឹងប្រែងរួមគ្នាក្នុងការលើកស្ទួយកិច្ចសហប្រតិបត្តិការ និងការតភ្ជាប់រវាងបណ្តាខេត្តតាមព្រំដែន*

-ចាប់ផ្តើមដំណើរការនូវគោលនយោបាយលើកកម្ពស់ និងអនុគ្រោះដល់ការវិនិយោគរួម ដើម្បីលើកទឹកចិត្តដល់សហគ្រិន និងវិនិយោគិន ឲ្យអនុវត្តនូវគម្រោងអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមនៅក្នុងប្រទេសនីមួយៗ។

-ស្វែងរកទុនវិនិយោគសម្រាប់កែលម្អ និងធ្វើឲ្យប្រសើរឡើងនូវហេដ្ឋារចនាសម្ព័ន្ធ ពិសេសហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន ពាណិជ្ជកម្ម និងបច្ចេកវិទ្យាព័ត៌មានវិទ្យានិងទូរគមនាគមន៍ (ICT) នៅក្នុងប្រទេសកម្ពុជា ឡាវ និងវៀតណាម ជាទូទៅ និងជាពិសេសតាមតំបន់ជាប់ព្រំដែន ដើម្បីធានាបាននូវហេដ្ឋារចនាសម្ព័ន្ធគ្រប់គ្រាន់ សម្រាប់ការអភិវឌ្ឍ និងការពង្រីកពាណិជ្ជកម្មតាមព្រំដែន។

-ពង្រីកទំនាក់ទំនង និងការផ្សព្វផ្សាយយន្តការនិងគោលនយោបាយទាក់ទងនឹង ការអភិវឌ្ឍពាណិជ្ជកម្មតាមព្រំដែន ការអភិវឌ្ឍនិងធ្វើឲ្យប្រសើរឡើងនូវប្រព័ន្ធទិន្នន័យគ្រប់គ្រងសកម្មភាពពាណិជ្ជកម្មតាមព្រំដែន ដើម្បីជាមាគ៌ា និងគ្រប់គ្រងសកម្មភាពពាណិជ្ជកម្មតាមព្រំដែននៃប្រទេសទាំងបីឲ្យបានទាន់ពេលវេលា។

-ពង្រឹងកិច្ចសហប្រតិបត្តិការលើការផ្លាស់ប្តូរព័ត៌មាន និងបទពិសោធន៍ រវាងអាជ្ញាធរពាក់ព័ន្ធ ដើម្បីសម្របសម្រួលដល់ការប្រយុទ្ធប្រឆាំងនឹងការរត់ពន្ធ បទល្មើសពាណិជ្ជកម្ម ការជួញដូរមនុស្ស និងការដឹកជញ្ជូនដោយខុសច្បាប់នូវទំនិញ ឈើ ថ្នាំញៀន (narcotics) សារធាតុប៉ះពាល់ផ្លូវចិត្ត (Psychotropic) សារធាតុគីមីសម្រាប់ផ្ញើមេ (precursor chemical) ប្រភេទសត្វព្រៃ និងរុក្ខជាតិ សម្បត្តិវប្បធម៌ ព្រមទាំងទំនិញខុសច្បាប់ ផ្សេងៗទៀត។

*២. ជំរុញទំនាក់ទំនងរវាងប្រជាជននិងប្រជាជន*

-រៀបចំវេទិកាទំនាក់ទំនងរវាងប្រជាជននិងប្រជាជន ក្នុង/ចំណោមប្រទេសទាំងបី ក្នុងឱកាសនៃការប្រារព្ធខួបសំខាន់ៗ ដើម្បីពង្រីកការយោគយល់គ្នា មិត្តភាព និងសាមគ្គីភាព រវាងប្រជាជននៃប្រទេសទាំងបី។

-វៀតណាមបន្តផ្តល់សេវាពិនិត្យ និងព្យាបាលជំងឺដល់ប្រជាជនកម្ពុជា និងឡាវ ព្រមទាំងបណ្តុះបណ្តាលបុគ្គលិកដែលកំពុងបម្រើការក្នុងវិស័យសុខាភិបាល នៅតាមបណ្តាខេត្តតាមព្រំដែនរបស់ប្រទេសកម្ពុជា និងឡាវ។

-ភ្ជាប់នូវសារៈសំខាន់នៃការអប់រំអំពី ប្រពៃណីសាមគ្គីភាព និងមិត្តភាព ក្នុងចំណោមយុវជននៃប្រទេសកម្ពុជា ឡាវ និងវៀតណាម រៀបចំឲ្យបានទៀងទាត់នូវកម្មវិធីយុវជនស្ម័គ្រចិត្តរួមប្រទេសកម្ពុជា ឡាវ និងវៀតណាម ដែលរួមចំណែកក្នុងការជួយប្រជាជននៅតំបន់ឆ្ងាយ និងដាច់ស្រយាល និងជាពិសេសតំបន់ដែលមិនមានភាពអំណោយផលរបស់ប្រទេសទាំងបី។

# ផ្នែកទី៤

# ធនធានហិរញ្ញវត្ថុ និងការរៀបចំការអនុវត្តការតភ្ជាប់

## I. ធនធានហិរញ្ញវត្ថុ

ធនធានហិរញ្ញវត្ថុសម្រាប់ប្រទេសទាំងបី ក្នុងការអនុវត្តកម្មវិធី និងគម្រោង ស្តីពីការតភ្ជាប់ស្ថាប័ន ការតភ្ជាប់ហេដ្ឋារចនាសម្ព័ន្ធ និងការតភ្ជាប់រវាងប្រជាជននិងប្រជាជន នឹងត្រូវពឹងផ្អែកលើប្រភព ដូចតទៅ៖ (១) ថវិកាជាតិរបស់ប្រទេសនីមួយៗ (២) ការវិនិយោគពីវិស័យឯកជនក្នុងប្រទេសទាំងបី (៣) ការឧបត្ថម្ភ និងកម្ចីសម្បទានពីស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ និងប្រទេសឬដៃគូអភិវឌ្ឍន៍ (៤) មូលធនបានមកពីភាពជាដៃគូរដ្ឋ-ឯកជន (PPP) និង (៥) ទីផ្សារហិរញ្ញវត្ថុ។

**១. មូលនិធិបានពីថវិកាជាតិ៖** ថវិកាជាតិនៅតែដើរតួជាធនធានហិរញ្ញវត្ថុដ៏សំខាន់មួយ សម្រាប់អនុវត្តគម្រោងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ កំណែទម្រង់ស្ថាប័ន និងការតភ្ជាប់រវាងប្រជាជននិងប្រជាជន រហូតដល់ឆ្នាំ២០៣០។ ប្រភពនៃមូលនិធិទាំងនេះ មានសារៈសំខាន់ជាចាំបាច់សម្រាប់គម្រោងដែលពុំសូវទទួលបានប្រាក់ចំណេញ ឬគម្រោងដែលទទួលបានផលចំណេញយឺត និងគម្រោងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធនៅតាមតំបន់ឆ្ងាយ តំបន់ដាច់ស្រយាល និងនៅតាមតំបន់ព្រំដែននៃប្រទេសទាំងបី។

**២. មូលនិធិបានពីវិស័យឯកជន និងភាពជាដៃគូរវាងរដ្ឋ-ឯកជន៖** ប្រភពមូលនិធិទាំងនេះមានសក្តានុពលខ្លាំង ក្នុងបរិបទដែលវិនិយោគិនបរទេសចាប់អារម្មណ៍លើទីផ្សារនៃប្រទេសទាំងបីមានការកើនឡើង។ ដើម្បីទាក់ទាញមូលនិធិពីវិស័យឯកជនសម្រាប់គម្រោងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ រដ្ឋាភិបាលនៃប្រទេសទាំងបីត្រូវតែជំរុញឲ្យកាន់តែខ្លាំងលើការអនុវត្តគម្រោងក្រោមរូបភាពភាពជាដៃគូរវាងរដ្ឋ-ឯកជន (PPP)។ ហេតុដូច្នេះ គួរធ្វើកំណែទម្រង់ស្ថាប័ន ដើម្បីធានាបាននូវដំណើរការ និងនីតិវិធីដែលមានតម្លាភាព។ យន្តការសម្រាប់ចែករំលែកហានិភ័យជាមួយវិនិយោគិន និងបញ្ជីនៃគម្រោង PPP ដ៏មានសក្តានុពលដែលអាចជឿជាក់បាន ក្នុងរយៈពេលចាប់ពីឆ្នាំ២០១៦ ដល់ ២០២០ និង ឆ្នាំ២០២០ ដល់ ២០៣០ នឹងត្រូវបានបង្កើតឡើង ដើម្បីទាក់ទាញវិនិយោគិន។

**៣. មូលនិធិបរទេស**សម្រាប់បង្កើតគម្រោង ជាពិសេសគម្រោងលើវិស័យដឹកជញ្ជូន ទូរគមនាគមន៍ និងហេដ្ឋា-រចនាសម្ព័ន្ធថាមពល រួមមានការវិនិយោគផ្ទាល់ពីបរទេស (FDI) ជំនួយអភិវឌ្ឍន៍ផ្លូវការ (ODA) ជាពិសេសកម្ចីសម្បទាន កម្ចីពាណិជ្ជកម្មពីស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ ដូចជា ធនាគារពិភពលោក ធនាគារអភិវឌ្ឍន៍អាស៊ី ធនាគារ

AIIB និងដៃគូអភិវឌ្ឍន៍ ដូចជា ចិន សហភាពអឺរ៉ុប ជប៉ុន កូរ៉េ សហរដ្ឋអាមេរិក និងប្រទេសផ្សេងៗទៀត។ ប្រទេសកម្ពុជា ឡាវ និងវៀតណាម អាចសម្របសម្រួលក្នុងការចាប់យកប្រភពមូលនិធិទាំងនេះ សម្រាប់គម្រោងដឹកជញ្ជូនឆ្លងកាត់ព្រំដែន និងហេដ្ឋារចនាសម្ព័ន្ធថាមពល។

៤. ក្រៅពីប្រភពមូលនិធិខាងលើ ប្រទេសកម្ពុជា ឡាវ និងវៀតណាម អាចចាប់យកជំនួយពី អង្គការអន្តរជាតិផ្សេងៗ ប្រទេសសមាជិកអាស៊ាន និងប្រទេសដៃគូអាស៊ាន ដើម្បីទទួលបានជំនួយបច្ចេកទេស សម្រាប់ធ្វើឲ្យប្រសើរឡើង និងពង្រឹងការតភ្ជាប់ផ្នែកទន់នៃប្រទេសទាំងបី រួមទាំង (តែមិនកំណត់ចំពោះ) ការគាំទ្រហិរញ្ញវត្ថុសម្រាប់ការបង្កើតយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិរបស់ប្រទេសកម្ពុជា ឡាវ និងវៀតណាម រហូតដល់ឆ្នាំ២០៣០ និងឆ្នាំបន្តបន្ទាប់ទៀត។ ជំនួយបច្ចេកទេសសម្រាប់រៀបចំការសិក្សាអំពីលទ្ធភាព និងបុរេលទ្ធភាព ក្នុងការបង្កើតគម្រោងហេដ្ឋារចនាសម្ព័ន្ធឆ្លងកាត់ព្រំដែន ការអនុវត្ត ការតាមដាន និងការវាយតម្លៃប្រសិទ្ធភាពនៃគម្រោង រួមទាំងការស្នើបញ្ជីគម្រោង PPP ដែលមានសក្តានុពល។

## II. ការរៀបចំអនុវត្ត

១. ដើម្បីអនុវត្តផែនការសកម្មភាពសម្រាប់ការតភ្ជាប់សេដ្ឋកិច្ច ប្រទេសទាំងបីចាំបាច់ត្រូវបង្កើតគណៈកម្មាធិការសម្របសម្រួលត្រីភាគីសម្រាប់ការតភ្ជាប់សេដ្ឋកិច្ច (Tripartite Coordination Committee - TCC)។ គណៈកម្មាធិការនេះគួរតែបង្កើតឡើងដោយធ្វើឲ្យប្រសើរឡើងទៅផ្អែកលើគំរូគណៈកម្មាធិការសម្របសម្រួលចម្រុះ (Joint Coordination Committee – CLV-DTA JCC) សម្រាប់កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍តំបន់ត្រីកោណ CLV-DTA។

២. នៅពេលបង្កើតរួច គណៈកម្មាធិការនេះត្រូវសហការជាមួយអន្តរក្រសួង-ស្ថាប័ន និងអាជ្ញាធរមូលដ្ឋានពាក់ព័ន្ធរបស់ប្រទេសទាំងបី បង្កើតបញ្ជីកម្មវិធី និងគម្រោងអាទិភាព សម្រាប់ការតភ្ជាប់សេដ្ឋកិច្ចរហូតដល់ឆ្នាំ២០៣០ ហើយទន្ទឹមនឹងនោះ បង្កើតនូវផែនការលម្អិតសម្រាប់ការសម្របសម្រួល និងតាមដានការអនុវត្តផែនការសកម្មភាពតភ្ជាប់សេដ្ឋកិច្ច រហូតដល់ឆ្នាំ២០៣០ ដោយក្រសួង-ស្ថាប័ន និងអាជ្ញាធរមូលដ្ឋានទាំងនោះ។

៣. នៅពេលផែនការសកម្មភាពត្រូវបានអនុម័តដោយថ្នាក់ដឹកនាំនៃប្រទេសទាំងបី គណៈកម្មាធិការ TCC និង CLV-DTA JCC ត្រូវសម្របសម្រួលជាមួយក្រសួង-ស្ថាប័ន និងអាជ្ញាធរមូលដ្ឋាននៃប្រទេសទាំងបី ដើម្បីរៀបចំ និងអនុវត្តកម្មវិធី និងគម្រោងសហប្រតិបត្តិការ និងតភ្ជាប់យ៉ាងជាក់លាក់រៀងៗខ្លួន តាមលំដាប់លំដោយ ត្រឹមឆ្នាំ២០២០ និងឆ្នាំ២០៣០ ដោយផ្អែកលើការពិគ្រោះយោបល់ជាមួយការស្នើសុំជំនួយ និងការគាំទ្រពីដៃគូអភិវឌ្ឍន៍ សហគមន៍ធុរកិច្ច និងប្រជាជនមូលដ្ឋាន។ គណៈកម្មាធិការសម្របសម្រួលថ្នាក់ជាតិ ក្រសួង-ស្ថាប័ន និងអាជ្ញាធរ

មូលដ្ឋាន ជាអ្នកទទួលខុសត្រូវក្នុងការសម្របសម្រួល និងមើលការខុសត្រូវលើការអនុវត្តផែនការ កម្មវិធី និងគម្រោងជាក់លាក់ នៅថ្នាក់ជាតិ និងមូលដ្ឋាន។

៤. ប្រទេសកម្ពុជា ឡាវ និងវៀតណាម ត្រូវសម្របសម្រួលអនុវត្តយុទ្ធសាស្ត្រទំនាក់ទំនងរួម សម្រាប់ផ្សព្វផ្សាយមាតិកានៃផែនការសកម្មភាពនេះ ទៅដល់គ្រប់ស្រទាប់ប្រជាជន ធុរកិច្ច/សហគ្រាស និងវិនិយោគិននៃប្រទេសទាំងបី ក៏ដូចជាជំរុញផែនការសកម្មភាពនេះ ដើម្បីតភ្ជាប់ប្រទេសទាំងបីទៅកាន់ប្រទេសសមាជិកអាស៊ានដទៃទៀត សម្រាប់ទទួលបានការគាំទ្រពីអ្នកផ្តល់ជំនួយ និងដៃគូអភិវឌ្ឍន៍អន្តរជាតិ សំដៅទាក់ទាញវិនិយោគិនឲ្យចាប់អារម្មណ៍គម្រោងតភ្ជាប់សេដ្ឋកិច្ចកម្ពុជា ឡាវ និងវៀតណាម។

៥. ផែនការសកម្មភាពសម្រាប់ការតភ្ជាប់សេដ្ឋកិច្ចកម្ពុជា ឡាវ និងវៀតណាម នឹងត្រូវពិនិត្យឡើងវិញជាប្រចាំឆ្នាំដោយ TCC សម្រាប់ការតភ្ជាប់សេដ្ឋកិច្ចកម្ពុជា-ឡាវ- វៀតណាម ហើយអាចនឹងត្រូវកែសម្រួលដោយមានការឯកភាពពីថ្នាក់ដឹកនាំនៃប្រទេសទាំងបី នៅក្នុងកិច្ចប្រជុំកំពូល និងបំពេញបន្ថែម ដើម្បីធានាថាមាតិកានៃផែនការសកម្មភាពនេះ មានភាពសមស្របទៅតាមលក្ខខណ្ឌ/ស្ថានភាព និងតម្រូវការពិតប្រាកដសម្រាប់ការតភ្ជាប់សេដ្ឋកិច្ចប្រទេសទាំងបីក្នុងរយៈពេលវែង រហូតដល់ឆ្នាំ២០៣០។

* * * * * * * * *

# ACTION PLAN FOR CAMBODIA-LAOS-VIET NAM ECONOMIC CONNECTIVITY UP TO 2030

# Content

Description Page

## Part 1

## BACKGROUND AND CONTEXT FOR CAMBODIA - LAOS -VIET NAM ECONOMIC CONNECTIVITY

**I. Background**........................................................................................... 1

**II. Context for CLV Economic Connectivity**.............................................................. 2

***2.1. Opportunities***......................................................................................... 2

***2.2. Challenges***............................................................................................ 3

**III. Major Problems to be Resolved**....................................................................... 3

***3.1. Institutional Connectivity***........................................................................... 3

***3.2. Infrastructure and Economic Connectivity*** .......................................................... 4

***3.3. People-to-people Connectivity***...................................................................... 4

## Part 2

## VIEWPOINTS, OBJECTIVES AND CONTENTS OF ECONOMIC CONNECTIVITY OF THE THREE COUNTRIES

**I. Viewpoints** ............................................................................................ 5

**II. Objectives**............................................................................................. 5

**III. Contents of connectivity**............................................................................. 6

## Part 3

## KEY STRATEGIES FOR ENHANCED

## CAMBODIA - LAOS – VIET NAM ECONOMIC CONNECTIVITY

**I. Institutional Connectivity** ........................................................................... 7

**II. Infrastructure Connectivity and Connectivity of Selected Important Economic Sectors** ............................................................................................. 8

***2.1. Transportation Infrastructure***...................................................................... 8

*2.2. Energy Infrastructure* ........ 9
*2.3. Posts and Telecommunications* ........ 9
*2.4. Investment* ........ 10
*2.5. Trade and Trade-related Matters* ........ 10
*2.6. Selected Industries* ........ 11
*2.7. Finance and Banking* ........ 13
*2.8. Natural Resources, Environment and Response to Climate Change* ........ 13
*2.9. Science and Technology* ........ 14
*2.10. Landmines/ UXO clearance* ........ 14
**III. People-to-people Connectivity and Border Area Cooperation** ........ 15
*3.1. Education and Training* ........ 15
*3.2. Health* ........ 15
*3.3. Cooperation in Labour Utilization* ........ 16
*3.4. Culture, Sports and Tourism* ........ 16
*3.5. Border Area Cooperation and People-to-People Connectivity* ........ 17

## Part 4

## FINANCIAL RESOURCES AND IMPLEMENTATION ARRANGEMENTS FOR CONNECTIVITY

**I. Financial resources** ........ 19
**II. Implementation Arrangements** ........ 20

# Part 1

# BACKGROUND AND CONTEXT FOR CAMBODIA - LAOS -VIET NAM ECONOMIC CONNECTIVITY

## I. Background

At the 8th Cambodia - Laos – Viet Nam Development Triangle Area Summit, (8th CLV-DTA Summit), held in Vientiane, Laos PDR on 25 November 2014, the Prime Minister of the Government of Viet Nam Nguyen Tan Dung proposed that the Government of the three countries of Cambodia - Laos – Viet Nam should take more flexible, practical, and efficient implementation measures to create breakthroughs and heighten trilateral cooperation. CLV Leaders have discussed and agreed to upgrade and expand the Cambodia - Laos - Viet Nam Development Triangle Area (CLV-DTA) cooperation framework and assigned the Joint Coordination Committee (JCC) to coordinate with relevant agencies to develop the Project for Economic Connectivity of the three countries, whereby the draft Action Plan for Economic Connectivity of the three countries shall be submitted for consideration and adoption at the 10th Cambodia - Laos - Viet Nam Development Triangle Area Summit (10th CLV-DTA Summit), to be held in March 2018 in Viet Nam.

Economic connectivity has become a major trend in the world in general and among the nations in the Asia region in particular. In Southeast Asia, the ASEAN Economic Community (AEC) was launched in the end of 2015, and regional countries have been actively implementing the Master Plan on ASEAN Connectivity 2025 (MPAC 2025). Major countries in the region such as China, Japan, USA, and others have proposed a series of cooperation initiatives to promote regional trade and value chains, which include the economic connectivity with the ASEAN countries. Meanwhile, Cambodia, Laos, and Viet Nam have been strongly developing and integrating into regional and global economies in an increasingly far-reaching manner. In addition to active participation in economic cooperation programs and initiatives within ASEAN framework, the three countries have also participated in the implementation of a series of sub-regional cooperation initiatives, such as "CLV Development Triangle Area (CLV-DTA), and CLMV cooperation (Cambodia, Laos, Myanmar, and Viet Nam), and Greater Mekong Sub-Region (GMS) program which have gained remarkable experiences and achievements. However, the results of cooperation and connectivity between the three economies are still not commensurate with the great potentials of the CLV. Some shortcomings in terms of institutional cooperation, infrastructure, and human resources remain, and consequently limiting the efficiency of economic cooperation and connectivity between the three countries over the past time.

Under the above context, the preparation and implementation of an action plan for CLV economic connectivity are urgent tasks and of great significance for facilitating the three economies to raise their competitiveness, and ability to attract foreign investment, to

narrow their development gap with other ASEAN member states, to accelerate economic connectivity within the AEC, and to integrate into the regional and global economies more efficiently.

## II. Context for CLV Economic Connectivity

### *2.1. Opportunities*

1. CLV leaders have a strong political determination for connecting three economies with an aim to heightening the level of cooperation between the three countries.

2. Economic connectivity has played an important role in facilitating the economic integration in the region. AEC is one of the three important pillars of ASEAN Community since late 2015. During the period 2011-2015, the countries in the region implemented MPAC 2025 and this Plan will be further implemented until 2025.

3. Cambodia - Laos - Viet Nam enjoy favorable advantages from geographical location, abundant natural and human resources, rich and diverse culture and share long borders with several border gate pairs and economic zones with relatively good infrastructure. The three countries are also located in important regional economic corridors such as China - Indochina Peninsula Economic Corridor on North-South axis; East-West Economic Corridor, Southern Economic Corridor etc. This strategic location ensures favorable advantages for promoting trade and tourism connectivity as well as enhancing the attractiveness to foreign direct investors.

4. The three countries have enjoyed long-standing and friendly neighboring relations and have recorded a number of noteworthy achievements in economic cooperation and connectivity. All the three countries have had a stable political situation with a dynamic economy with high growth rate. This is not only a necessary condition for ensuring Cambodia, Laos and Viet Nam to realize economic connectivity, but also a foundation for the three countries to connect with each other for enhancing their competitiveness against the other economies in the region and attractiveness for foreign investors.

5. Cambodia, Laos and Viet Nam are the three economies sharing economic cooperation and connectivity benefits. In addition, the three economies have enjoyed the potentials to complement each other. For example, Laos has a great potential in hydropower, while Cambodia has a demand for imported electricity. Laos is a landlocked country, while Cambodia and Viet Nam have coastlines with a great potential for development such as seaport, maritime transport, seafood and marine tourism, etc.

6. The three countries have all been stepping up regional and international economic integration, especially participation in new generation of Free Trade Agreements (FTAs). The three countries have had experience in long-term trilateral cooperation under the framework of CLV Development Triangle Area Initiative and have recorded remarkable achievements. This is a very important prerequisite for boosting trilateral economic connectivity in the coming time.

7. Development strategies and plans of the three countries give priority to infrastructure and human development and institutional reform.

### *2.2. Challenges*

1. Financial resources of CLV countries are limited due to the fact that all the three countries are the economies of small scale in the region and the world. Their competitiveness, development level, openness, innovation capacity and private sector generally remain weak. This will constrain the ability to realize trilateral economic connectivity projects.

2. Transport, trade, and energy infrastructure of the CLV countries remain insufficient and weak in general, creating difficulties for cooperation and connectivity in other areas, particularly tourism, trade, and people-to-people connectivity.

3. Some differences among the CLV countries still remain. For example, private sector in Cambodia has played a greater role than that in Laos and Viet Nam. With regard to the degree of openness and international integration, and international integration mindset, there have also certain differences among the CLV countries.

4. The fact that major countries try to increase their competition and influence in ASEAN region has negatively affected the internal linkages in ASEAN in general and the CLV countries in particular, thus reducing the need for economic connectivity among the CLV countries.

5. The CLV countries have abundant human resources and low labor cost, but their human resources' qualification has still been inadequate and failed to meet the requirements for economic cooperation, connectivity and integration in the future.

6. The three countries have been affected from protracted sequence of regional conflicts that result in landmines and UXOs. The three countries reaffirmed their commitments to further strengthening the cooperation to ensure the security, safety and landmines-UXO clearance in order to support all development projects in each country and contribute to the sustainable socio-economic development.

## III. Major Problems to be Resolved

### *3.1. Institutional Connectivity*

(1) There have still existed some differences among the CLV countries regarding cooperation mechanism and legal provisions related to investment, trade, finance, banking, taxation, and labor. For example, cross-border freight charges of the three countries are different and higher than the ASEAN regional average, mainly due to poor infrastructure, complicated trade procedures, and incompatible logistics services. In the investment sector, procedures have remained cumbersome; land policies and policies for foreign investors remain inconsistent. Therefore, addressing the above-mentioned institutional differences will be time consuming.

(2) Cooperation in the area of institutional, infrastructure and people-to-people connectivity in the CLV-DTA over the past has not brought about desired results. This reduces the confidence and creates difficulties in opening up new cooperation mechanisms among CLV countries.

(3) There are currently many different connectivity initiatives that are implemented in ASEAN countries in general and in CLV in particular. However, simultaneous realization of Regional Comprehensive Economic Partnership (RCEP) with the participation of ASEAN will also exert a significant impact on CLV bilateral and multilateral relations.

(4) Moreover, CLV trilateral cooperation mechanisms and programs remain very limited. Cooperation activities in the past years were mainly in the form of bilateral cooperation between Cambodia, Laos and Viet Nam.

### *3.2. Infrastructure and Economic Connectivity*

(1) The ideas and resources for CLV cooperation and connectivity mainly come from the Governments of the three countries. Private sector's involvement in terms of both ideas and resources remain limited and inefficient.

(2) Infrastructure connectivity between the three countries, especially transport, trade, and energy infrastructure, still faces various difficulties and remains insufficient. This reduces the overall competitiveness of the three countries and limits the connectivity in other relevant areas, particularly tourism, trade, and people-to-people connectivity. This is a weakness that is not easy to overcome because modernizing and building a synchronous infrastructure system requires huge time and capital.

(3) Practices in economic cooperation and connectivity between CLV over the past time indicate ineffectiveness in many bilateral and trilateral economic cooperation projects and areas. This may reduce the confidence for cooperation in the coming period.

### *3.3. People-to-people Connectivity*

(1) Many barriers remain to be seen in cross-border procedures and regulations of the three countries, such as procedures for visa granting, employee registration, customs procedures, constraining exchanges and cooperation of the people as well as cross-border flow of goods and people.

(2) Financing for people-to-people connectivity activities remains limited under the context of CLV countries that are the poor ones, especially the border provinces of the three countries are among their poorest provinces.

(3) There have not yet been long-term projects that are of strategic importance available for people-to-people connectivity, thus failing to attract the participation of business community, especially that of the private sector, and the active support of partners and international organizations as well.

# Part 2

## VIEWPOINTS, OBJECTIVES AND CONTENTS OF ECONOMIC CONNECTIVITY OF THE THREE COUNTRIES

### I. Viewpoints

1. In this Action Plan, the concept of "economic connectivity" means: Enhancing coordination to address differences and obstacles; create cohesion and smoothness in the cooperation of the CLV economies in such major areas as institution, infrastructure, and people-to-people.

2. CLV economic connectivity shall be based on the principle of mutual respect for independence, sovereignty, territorial integrity, and support and facilitation of mutual development; achieving high consensus of the Government and the people of the three countries.

3. Contents of economic connectivity between the three countries shall be in line with international practices, bilateral cooperation commitments, especially those in ASEAN, and the laws and regulations of each country.

4. CLV economic connectivity shall be based on the principle of feasibility with a focus on the priority areas of potential and advantages by related parties that can be effectively complementary to each other; great importance shall be attached to the overall interests, integration strategy, long-term development of the three countries.

5. CLV economic connectivity must be realized at a greater pace, in a more profound manner and with higher quality than the three countries' connectivity commitments within the framework of ASEAN Community.

### II. Objectives

1. Create favorable infrastructure, institutional clarity, culture, and tourism, and people understanding among the three countries, thus strengthening and modernizing of transport infrastructure, agriculture, energy, and communications connectivity accordingly; promote the simplification of the processes and procedures for making easier cross-border movement of goods and people according to the law and regulations of each country; and enhance exchanges and understanding between the peoples of the three countries.

2. Connect the three economies in order to promote cooperative, peaceful, friendship, and mutually beneficial relations for prosperity of the three countries.

3. Economic connectivity shall create a driving force for socio-economic development in each country as well as lay the foundation for the three countries of CLV

to integrate into ASEAN community, especially ASEAN Economic Community and for their more profound and more efficient regional and international integration.

## III. Contents of connectivity

**1. Institutional Connectivity** comprises increased policy communications and exchanges of information among the three countries; coordination in developing and implementing macro policies; further acceleration of applying customs procedures and trade facilitation in ASEAN and tariff reduction schedule in ASEAN Trade in Good Agreement (ATIGA), removing regulatory barriers to cooperation simplifying procedures to promote investment, trade, tourism, agriculture, transport, human resource training/development and management, creating a favorable environment for citizens and businesses of the three countries to cooperate for mutual benefit.

**2. Infrastructure Connectivity** focuses on upgrading, modernizing and ensuring convenient and smooth connectivity of all kinds of transportation, information and telecommunications, energy, trade, agriculture, and tourism related infrastructure among the three countries of CLV.

**3. People-to-people Connectivity** includes connectivity in the fields of education, health, culture, sports, tourism, entrepreneurship, charity activities, human resource training/development, and management enhancing people exchange and sister cities activities between local agencies and organizations of the three countries. Institutional reforms shall be actively promoted for removing barriers to cross-border movement of people and facilitating the above areas of cooperation.

# Part 3

## KEY STRATEGIES FOR ENHANCED CAMBODIA - LAOS – VIET NAM ECONOMIC CONNECTIVITY

### I. Institutional Connectivity

1. Enhance policy communications and exchanges among the three countries, including development strategy orientations, macro-economic orientations, international integration orientations; coordination in formulating medium and long-term development master plans and plans among the three countries, common statistical data in a number of socio-economic and environmental areas; active exchange of policy information in the areas related to investment, trade, taxation, customs, statistics.

2. Enhance exchange of experience and coordination in developing and implementing macroeconomic policies, such as experience in stabilizing the local currency exchange rate and controlling inflation, cooperation with international financial institutions in preventing financial and monetary risks; exchange of experience in computing Gross Domestic Product (GDP) and Gross Regional Domestic Product (GRDP).

3. Build up a favorable environment and policy framework for promoting investment and trade activities, assisting the three countries to resolve problems, accelerating implementation progress of the projects that have been licensed; provide orientation guidance on investment cooperation forms and areas to localities and businesses. Therefore, Cambodia and Viet Nam should conclude the Agreement for the Avoidance of Double Taxation as early as possible. As regard trade, the three countries had concluded the negotiations on Trade Promotion and Facilitation Agreement for Cambodia - Lao PDR - Viet Nam Development Triangle Area and it was signed in November 2016.

4. Strengthen the reform of administrative procedures related to investment and business towards simplicity, compatibility, publicity, transparency and consistency in the whole territory of each country, reducing troubles and difficulties for businesses. In the long term, a study should be conducted to reach an agreement upon some common regulations and policies within the three countries, such as investment incentive policies, policies on trade facilitation, tax incentives, and labour recruitment for businesses of the three CLV countries.

5. Further accelerate the application of international standards of customs procedures that have been agreed to be consistently applied within ASEAN in accordance with the spirit of MPAC 2025.

## II. Infrastructure Connectivity and Connectivity of Selected Important Economic Sectors

### *2.1. Transportation Infrastructure*

(1) Construct, rehabilitate, and upgrade transit routes connecting the three countries to meet minimum standards of grade III of ASEAN. Conduct studies for building the shortest route to connect the capitals of the three countries. Ensure that each border province of each country has a route connecting to each other. Jointly conduct feasibility studies for building expressways to connect the three countries, especially for the connection of economic and tourist centers/areas.

